មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ ស៊ីន សារឿន ភេទប្រុស អាយុ៥៧ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ ពេទ្យកងពល៨០១**

**ស្រុកកំណើតនៅភូមិចុងកោះ ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្ដាល**

**រស់នៅភូមិទំនប់ដាច់ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ**

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី និង ឌី ខាំបូលី**

**០១:៥២:៣៥**

**៥៨ទំព័រ**

ដានីៈ ដឹបូនចង់ស្គាល់ឈ្មោះពូពេញ ឈ្មោះអី?

សារឿនៈ ខ្ញុំឈ្មោះពេញ ឈ្មោះ ស៊ីន សារឿន ។

ដានីៈ ស៊ីន សារឿន?

សារឿនៈ បាទ ។

ដានីៈ អាយុប៉ុន្មានហើយ?

សារឿនៈ អាយុសព្វថ្ងៃកើតឆ្នាំ១៩៥៦ គិតទៅវាស្មើរនឹង៥៧ឆ្នាំ ។

ដានីៈ ៥៧ឆ្នាំ?

សារឿនៈ បាទ ។

ដានីៈ ស្រុកកំណើតកើតជានៅណាដែរ?

សារឿនៈ ស្រុកកំណើតខ្ញុំនៅស្រុកស្អាង ខេត្តកណ្ដាល ។

ដានីៈ ភូមិអីដែរ?

សារឿនៈ នៅភូមិចុងកោះ ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្ដាល ។

ដានីៈ សព្វថ្ងៃពូរស់នៅក្នុងភូមិ ឃុំ ស្រុកអីដែរ?

សារឿនៈ ខ្ញុំរស់នៅក្នុងភូមិទំនប់ដាច់ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ។

ដានីៈ គ្រួសារឈ្មោះអីដែរលោកពូ?

សារឿនៈ គ្រួសារខ្ញុំឈ្មោះ មិត្ត ចាន់ថា ។

ដានីៈ គាត់អ្នកស្រុកណាដែរ?

សារឿនៈ ស្រុកកំណើត?

ដានីៈ បាទ ។

សារឿនៈ ស្រុកកំណើតអ្នកភូមិស្វាយ ឃុំរកា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

ដានី៖ អ្នកខេត្តកណ្ដាលដូចគ្នា?

សារឿន៖ បាទ ។

ដានី៖ គាត់អាយុប៉ុន្មានហើយ?

សារឿន៖ គាត់អាយុ៥៨ឆ្នាំ ឆ្នាំនេះហើយ ។

ដានី៖ ៥៨ឆ្នាំ?

សារឿន៖ បាទ! ៥៨ ។

ដានី៖ លោកពូមានកូនចៅប៉ុន្មាននាក់ដែរ?

សារឿន៖ កូនខ្ញុំមាន៣នាក់ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សារឿន៖ ស្រី១ ប្រុស២ ។

ដានី៖ គាត់ធំៗអស់ហើយ?

សារឿន៖ ធំហើយ កូនច្បងមានកូន៣នាក់ហើយ ។

ដានី៖ គាត់រៀនសូត្រដល់ណាដែរ?

សារឿន៖ កូនច្បងរៀនថ្នាក់ទី៦ទេ ហើយកូនទី២ រៀនជាប់បាក់ឌុប ហើយកូនទី៣ពៅគេ នៅរៀនភ្នំពេញនេះឆ្នាំទី១ ទើបរៀនចូលឆ្នាំទី១ ។

ដានី៖ ខាងសាលាណាដែរ?

សារឿន៖ នៅសាលាវ៉ាន់ដា ។

ដានី៖ វ៉ាន់ដាគណនេយ្យ?

សារឿន៖ បាទ! វ៉ាន់ដាគណនេយ្យ ។

ដានី៖ ហើយកូនទី២ គាត់?

សារឿន៖ គាត់ធ្វើប៉ូលីសនៅព្រំដែន ។

ដានី៖ ប៉ូលីសព្រំដែន?

សារឿន៖ បាទ! ប៉ូលីសព្រំដែន តែមានប្រពន្ធហើយ ។

ដានី៖ កូនស្រីបងគេ?

សារឿន៖ កូនស្រីបងគេ នេះផ្ទះ ។

ដានី៖ លោកពូគិតចង់ឲ្យកូនទី១ រៀនបានត្រឹមថ្នាក់ទី៦?

សារឿន៖ បាទ ។

ដានី៖ កូនទី២ បានបាក់ឌុបហើយបានធ្វើប៉ូលីស?

សារឿនៈ បាទ! ធ្វើប៉ូលីស ។

ដានីៈ ដល់កូនទៅរៀនបានច្រើនដាងគេ?

សារឿនៈ បានច្រើនដាងគេ ។

ដានីៈ លោកពូខ្លួនឯងកាលពីក្មេងៗ រៀនដល់ណាដែរ?

សារឿនៈ ខ្ញុំពីក្មេង នៅពីសម័យសម្តេចឪ ជាសង្គមចាស់ចុះ ខ្ញុំរៀនបានថ្នាក់ទី៨ ជំនាន់សម្តេចឪ ។

ដានីៈ ទី៨ "ចាស់"?

សារឿនៈ បាទ! ទី៨ "ចាស់" ។

ដានីៈ ពីឆ្នាំណាដល់ឆ្នាំណា ទី៨?

សារឿនៈ ខ្ញុំរៀនបាន៥ឆ្នាំ រៀនពីឆ្នាំ៦៥-៦០ ។

ដានីៈ ៦៥?

សារឿនៈ ពីឆ្នាំ៦៥ រៀនដល់ឆ្នាំ៧០ ថែ៥ឆ្នាំគត់ខ្ញុំបានរៀន ។

ដានីៈ រៀនបាន៥ឆ្នាំ?

សារឿនៈ បាទ! ៥ឆ្នាំ ។

ដានីៈ កាលហ្នឹងដូចថាពីឆ្នាំ៦៥-៧០ ឆ្នាំ៧០ លោកពូឈប់?

សារឿនៈ បាទ! នោះគេរដ្ឋប្រហារសម្តេចទៅ ខ្ញុំក៏អត់មានសាលារៀនក៏ឈប់ ។

ដានីៈ ឈប់នេះដោយសាររដ្ឋប្រហារអត់មានសាលារៀន?

សារឿនៈ រដ្ឋប្រហារអត់មានសាលា អត់មានគ្រូ ។

ដានីៈ កាលរៀនហ្នឹងរៀនក្នុងភូមិនៅស្រុកកំណើត?

សារឿនៈ ខ្ញុំរៀននៅស្រុកកំណើត នៅវត្តចាស់ ។

ដានីៈ រៀននៅវត្តចាស់? សាលាវត្តចាស់?

សារឿនៈ បាទ!

ដានីៈ កាលហ្នឹងដល់ថ្នាក់ទី៨ យើងចេះអាន ចេះសរសេរអីច្បាស់?

សារឿនៈ បាទ! ចេះអាន សរសេរកើត ។

ដានីៈ ច្បាស់?

សារឿនៈ បាទ!

ដានីៈ កាលហ្នឹងលោកពូដូចថា ក្នុងចិត្តកាលពីក្មេង ឬឪពុកម្តាយធ្លាប់មានណែនាំថា កូនចង់រៀនដល់ត្រឹមណា ឬចង់ធ្វើអី? ដល់ពេលធំឡើង មានដែលមានបំណងប្រាថ្នាអីចឹងទេ?

សារឿនៈ បាទ! ឪពុកម្ដាយរបស់ខ្ញុំអត់មានការសោកស្ដាយ បន្ទិច្ឆ្ងៀវរៀនយ៉ាងម៉េចទេ តែសំរាប់ខ្ញុំចង់រៀនធ្វើគ្រូសម័យនោះ ។

ដានីៈ ចង់ធ្វើគ្រូ?

សារឿនៈ បាទ! ចង់ធ្វើគ្រូ ព្រោះគ្រូជាមនុស្សម្នាក់នៅក្នុងសង្គម អត់មានទៅស៊ីឈ្នួលអ្នកណាទេ ធ្វើដោយភ្នាក់រំលឹក ដោយស្មារតីទទួលខុសត្រូវ ចង់ឲ្យសិស្សានុសិស្សយល់ដឹងពីយើងចេះរៀនអក្សរ ។

ដានីៈ កាលហ្នឹងលោកពូគិតថា មានបំណងចង់ធ្វើគ្រូ តែបំណងហ្នឹងយ៉ាងម៉េចវិញទៅ?

សារឿនៈ បំណងហ្នឹងវាចប់ត្រឹមឆ្នាំ៧០ សមត្ថភាព អក្សរសាស្ត្រយើងទៅមិនដល់ ទៅបានត្រឹមហ្នឹងក៏ចប់ទៅ កើតបដិវត្តន៍មកយើងនៅក្នុងតំបន់បដិវត្តន៍ហើយស្រេច ។

ដានីៈ លោកពូមានបងប្អូនប៉ុន្មាននាក់ដែរ?

សារឿនៈ បងប្អូនខ្ញុំមាន៩នាក់ ។

ដានីៈ បងប្អូន៩នាក់?

សារឿនៈ បាទ! ស្រី២ ប្រុស៧ ។

ដានីៈ ក្នុងចំណោមបងប្អូន៩នាក់ហ្នឹង បានរៀនសូត្រអី?

សារឿនៈ បងប្អូនខ្ញុំទាំងអស់រៀនសូត្របានត្រឹមថ្នាក់ទី៧, ទី៨ទាំងអស់ អត់តែម្នាក់ទេ រៀនបានថ្នាក់ទី១០ពីសង្គម ។

ដានីៈ ៩នាក់ ប្រុស៧ ស្រីតែ២?

សារឿនៈ ស្រី២ ។

ដានីៈ លោកពូកូនទីប៉ុន្មានទៅ?

សារឿនៈ ខ្ញុំកូនទី៦ ។

ដានីៈ ឪពុកលោកពូគាត់ឈ្មោះអីទៅ?

សារឿនៈ ឪពុកខ្ញុំឈ្មោះ ស៊ីង អួន ។ ម្ដាយខ្ញុំឈ្មោះ សុខ ឆុំ ។

ដានីៈ សព្វថ្ងៃគាត់នៅរស់ ឬខូចហើយ?

សារឿនៈ គាត់ខូចអស់ហើយ ។

ដានីៈ ខូចតាំងពីជំនាន់ណាទៅ?

សារឿនៈ ឪពុកខ្ញុំស្លាប់នៅក្នុងឆ្នាំ៨២ ម្ដាយខ្ញុំស្លាប់ឆ្នាំ២០០៣ ។

ដានីៈ លោកពូអីចឹងដល់ពេលលោកពូឈប់រៀនឆ្នាំ៧០ហើយ លោកពូធ្វើអីទៀតទៅ?

សារឿនៈ ឈប់ឆ្នាំ៧០ខ្ញុំនៅផ្ទះជួយធ្វើស្រែ ចំការ ស្រុកយើងទន្លេរកត្រីដោះស្រាយជីវភាព ហើយដាំថ្នាំ ស្រុកទន្លេធម្មតាធ្វើរដូវប្រាំងដែរ ។ ដល់ពេលឆ្នាំ៧២ខ្ញុំចូលបដិវត្តន៍នឹងគេមក ឆ្នាំ៧២ ខែ២ ខ្ញុំចូលធ្វើបដិវត្តន៍ ។

ដានីៈ លោកពូចូលធ្វើបដិវត្តន៍ហ្នឹងស្ម័គ្រចិត្ត ឬយ៉ាងម៉េចដែលពេលហ្នឹង?

សារឿនៈ អត់ទេ ការចូលនេះធ្វើដោយស្ម័គ្រចិត្ត ព្រោះដោយសារគាំទ្រសម្តេចឪ អីចឹងនឹកឃើញ និស្ស័យជួយសម្តេចឪឲ្យលោកមកសោយរាជ្យវិញ ហើយចលនាហ្នឹងគេនិយាយអីចឹងចេះ តែទៅរួចតាមហ្នឹង ។

ដានីៈ ចូលហើយលោកពូទៅណា? យើងធ្វើអីខ្លះទៅ?

សារឿនៈ ចូលឆ្នាំ៧២នេះខ្ញុំនៅធ្វើកងស្រុកស្អាងដល់ឆ្នាំ៧៣ ក្រោយពេលឆ្នាំ៧៣ ខែ៩ គេបាន បញ្ជូនខ្ញុំមកនៅភូមិភាគពិសេស គេថាភូមិភាគពិសេសនៅខាងជើងភ្នំពេញ យើងម្តុំទំនប់ បាក់ ដំណាក់រាំង ត្រពាំងស្វាប់ ខ្សាច់ពូន យើងបាត់កូន អន្តព្រលឹង បង១ស្គាល់ហ្នឹង អាចខ្ញុំនិយាយទៅចាំ និយាយរួមហៅភ្នំត្នោតពង គេបញ្ជូនមកនៅហ្នឹង ធ្វើសឹក ធ្វើសង្គ្រាម នៅតាមជិនារខាងជើងភ្នំពេញហ្នឹងទៅ ។

ដានីៈ លោកពូកាលគេបញ្ជូនមកភូមិភាគពិសេស លោកពូនៅក្នុងកងទ័ព ឬជា?

សារឿនៈ ខ្ញុំនៅក្នុងទ័ពស្រុកស្អាង តែសម័យនោះគេដាក់ឈ្មោះថាស្រុក២០ គេឲ្យឈ្មោះស្រុក២០ លេខវា ។

ដានីៈ ស្រុកស្អាងហ្នឹងក្នុងភូមិភាគពិសេសឬយ៉ាងម៉េច?

សារឿនៈ ស្រុកស្អាងនេះបើតាមគិតទៅនៅក្នុងភូមិភាគពិសេស វាមិនមែននៅក្នុងបូព៌ាទេ ខាងបូព៌ាគេ កាត់ខាងកើតទន្លេ ស្អាងនេះគេកាត់មកភូមិភាគពិសេស ហើយមួយកំណាត់ទៅចេះបានគេ កាត់មកខាងនិរតី គេមានកំរង់គេ ខាងត្បូងភ្នំពេញ ខាងជើងភ្នំពេញតិចហ្នឹង នៅក្នុង ភូមិភាគពិសេស ។ ៩ ២៥

ដានីៈ ដល់ពេលលោកពូថាគេបញ្ជូនមកភូមិភាគពិសេស មកខាងត្នោតពង យើងនៅក្នុងកងទ័ព ស្រុកស្អាងទៀត ឬគេផ្លាស់ប្តូរហើយ?

សារឿនៈ អត់មានទេ ខ្ញុំមកនៅក្នុងភូមិភាគពិសេស គេបង្កើតជាកងវរៈ ឈ្មោះថាវរ១៣៤ វរៈ របស់ខ្ញុំនៅក្នុងកងពល១៤ វរសេនាធំគេហៅវរសេនាធំទី១ ។

ដានីៈ កងពល១៤ មានវរសេនាធំប៉ុន្មានទៅ?

សារឿនៈ មាន៤វរសេនាធំ ។

ដានីៈ វរសេនាធំទី១?

សារឿនៈ គេហៅ“វ” កាលហ្នឹងគេហៅវ-១ របស់ខ្ញុំ វ-២, វ-៣ និងវ-៤ មួយសារវៃ ត្រពាំងព្រាយ គេបង្កើតមួយ“វ”ទៀត គេហៅវ-៤ ។ ជិតនាំយុទ្ធមិត្តសាយ បើបានលឺ យុទ្ធមិត្តសាយហ្នឹងនៅវ-៤ហើយ ។

ដានីៈ យុទ្ធមិត្តសាយក្នុង?

សារឿនៈ ក្នុងកងវរសេនាធំវ-៤ ។

ដានីៈ កាលហ្នឹងពេលដែលលោកពូបញ្ជូនមកឆ្នាំ៧៣ហ្នឹង មកក្នុងកងពល១៨ហ្នឹង?

សារឿនៈ បាទ មកនៅកងពល១៨ ។

ដានីៈ កងពល១៨ហ្នឹងគេបង្កើតហើយក្នុងឆ្នាំ៧៣?

សារឿនៈ គេបង្កើតហើយ ខ្ញុំមកខ្ញុំរៀននៅសាលាហ្វឹកហ្វឺនកងទ័ពហ្នឹងហើយ កងពល១៨គេបង្កើត នៅពេលឆ្នាំ៧៣នោះ ក៏រៀបបញ្ចូលទៅក្នុងកងពល១៨ហ្នឹងទៅ ។

ដានីៈ សមាភាពពីណាខ្លះទៅដូចជាខាងគណៈកងពល?

សារឿនៈ គណៈកងពលកាលនោះខ្ញុំមិនចាំអស់ទេ ខ្ញុំចាំតា០៥ តាសូ សារឿន គេហៅ០៥ ហ្នឹងបញ្ជាការ ហើយរងនោះតាសាន គេហៅ០៦ ។

ដានីៈ ពីណាទៀតនៅក្នុងកងពល?

សារឿនៈ នៅក្នុងកងពលមានតែ២ហ្នឹងទេ គេរៀបថ្មីទៀតអត់ទាន់បង្កើត ។

ដានីៈ ចុះវ-១វិញពីណាគេវិញ?

សារឿនៈ វ-១ វរសេនាធំឈ្មោះ តាម៉ូត?

ដានីៈ ឈ្មោះ ម៉ូត?

សារឿនៈ បាទ ឈ្មោះម៉ូត ហើយរងគាត់ឈ្មោះតាសុន និងឈ្មោះតាគី ក្រោយមកទៀតឈ្មោះ តាឈួន សម័យនោះមិនចាំប្រវត្តិសាវតារនាមត្រកូលអីទេ គ្រាន់តែយើងស្គាល់អីចឹង ។

ដានីៈ ហើយវ-២?

សារឿនៈ វ-២ ខ្ញុំអត់ស្គាល់ឈ្មោះគេទេ ។

ដានីៈ វ-៣?

សារឿនៈ អត់ទេ ។

ដានីៈ វ-៣, វ-៤ ក៏អត់ដែរ?

សារឿនៈ អត់ទេ អត់ស្គាល់ទាំងអស់ ។

ដានីៈ កាលហ្នឹងពេលដែលលោកពូមកខាងត្បូងតពង កាលហ្នឹងកងពល១៨ទីតាំងនៅកន្លែងណា ទៅ?

សារឿនៈ កងពល១៨ តាមពិតកងពលអត់មានទីតាំងទេ រស់នៅចល័ត កងទ័ពក៏នៅចល័តដែរ បើអង្គភាពខ្ញុំគេបញ្ជូនទៅខាង នៅខាងឡូឝ្យូងយើងបែកចាន រៀបហើយគេឲ្យនៅឡូឝ្យូងបែកចាន យើងខាងជើងភ្នំពេញបន្តិច តាមផ្លូវលេខ២១ ជួនកាលគេដកទៅបាត់កូនទៅ ជួនកាលខ្លះទៅនៅលង្វែក មួយវរសេនាធំខ្លះទៅនៅលង្វែក អីចឹងវានៅអត់ទៀងទាត់ទេ សម័យនោះចល័ត ទីបញ្ជាការអត់មានទេ។

ដានីៈ មួយទៀតលោកពូខាងកងពល១៨ហ្នឹង សមាភាពកងទ័ពច្រើនមកពីខាងណាខ្លះទៅ?

សារឿនៈ សមាភាពកងទ័ពនៅកងពល១៨ ភាគច្រើនអ្នកមកពីត្បូងភ្នំពេញ អ្នកខេត្តកណ្ដាលភាគច្រើន។

ដានីៈ ខាងខេត្តកណ្ដាល ស្រុកអីខ្លះទៅ?

សារឿនៈ ខេត្តកណ្ដាលវាមានចំរុះគ្នា តាំងពីស្រុកកោះធំ ស្រុកលើកដែកក៏មាន ស្រុកកៀនស្វាយក៏មាន វាមានចំរុះគ្នា ហើយវាមានមកពីខេត្តកំពង់ស្ពឺក៏មាន គេហៅតំបន់១៥ វាលាយគ្នា។

ដានីៈ អីចឹងភាគច្រើននៅខេត្តកណ្ដាល ដូចលោកពូមានប្រសាសន៍មិញ ហើយនៅតំបន់១៥?

សារឿនៈ បាទ!

ដានីៈ មានសមាសភាពណាដែលបញ្ចូលមកទៀតដែល ចូលទៅកងពល?

សារឿនៈ មានទៅពីនេះដែរ មានកងវរ១៣៩ ចេញពីកំពង់ធំនេះទៅ ទៅចូលក្នុងកងពលហ្នឹង។

ដានីៈ ចេញពីកំពង់ធំទៅ?

សារឿនៈ បាទ! ចេញពីកំពង់ធំទៅ ១៣៩។

ដានីៈ ១៣៩ នៅក្នុង«វ»ប៉ុន្មានទៅ?

សារឿនៈ ១៣៩ហ្នឹងគេបញ្ចូលទៅដំបូងនៅក្នុង«វ»របស់ខ្ញុំ នៅវរៈជាមួយខ្ញុំ។

ដានីៈ ពីកំពង់ធំទៅ?

សារឿនៈ បាទ! ពីកំពង់ធំទៅ។

ដានីៈ គាត់ជាខ្មែរយើង ឬក្រុមខាងជនជាតិ?

សារឿនៈ គាត់ជាខ្មែរ កងទ័ពខ្មែរ។

ដានីៈ មិនមែនជនជាតិភាគតិច?

សារឿនៈ អត់មានជនជាតិទេ កំពង់ធំយើង ខ្មែរយើង។

ដានីៈ ខ្ញុំយល់ តែមានកងពលខ្លះ ដូចថាចេញពីភាគឥសានចូលទៅកំពង់ធំហើយ ចូលទៅខាង?

សារឿនៈ កាលហ្នឹងអត់ទាន់មានបងប្អូនឥសានទេ ដល់ក្រោយឆ្នាំ៧៥បានមានបងប្អូនឥសានលាយឡំគ្នា។

ដានី៖ លោកពូមកខាងត្បូងរហូតដល់ពេលណាទៅ? ពេលដែលលោកពូចូលក្នុងវរ១៣៩?

សារឿន៖ ខ្ញុំនៅក្នុងវរ១៣៩រហូតដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំគេឲ្យនៅនឹងផ្សារដើមគរ ហើយទៅយាមប៉ុស្តិ៍វិទ្យុនៅស្ទឹងមានជ័យ ប៉ុស្តិ៍វិទ្យុជាតិខ្ញុំចល័ត ពេលនោះខ្ញុំគេឲ្យមានកិច្ចការងារមួយដែលខ្ញុំខាងចល័ត គេឲ្យធ្វើពេទ្យសំរាប់អង្គភាព គេឲ្យខ្ញុំរៀនពេទ្យសម័យនោះ ពេទ្យកងទ័ពចេះតែរុំ ចេះតែចាក់ ចេះតែរៀន កាលនោះខ្ញុំរៀនជាមួយ តាជួនជឿន បាន៣ខែយកមកប្រើការ អីចឹងខ្ញុំចេះចល័តពីស្ទឹងមានជ័យមកផ្សារដើមគរមកទល់ ពីនោះគេហៅមាន់ថែរ ខាងជើងអាងទឹកស្អាត កែងអាងទឹកស្អាត ។

ដានី៖ ក្បាលមាន់ថែរ?

សារឿន៖ បាទ! ក្បាលមាន់ថែរ ដល់ខែ១១-១២ និយាយរួមកាលខ្ញុំចេញពីនោះខែកក្កិក គេរំលាយអង្គភាពរបស់ខ្ញុំហ្នឹង មួយវរសេនាធំ វ-១គេរំលាយចោលទាំងអស់ គេយកទៅដាក់ក្នុងវរសេនាធំទី១ ទី២ ទី៣ ។ វរសេនាធំខ្ញុំគេរំលាយចោល ហើយគេដកពួកខ្ញុំដែលជាពេទ្យទាំងអស់នេះទុកម្តុំសម័យនោះ ទុកម្តុំគេឲ្យនៅស្អាតយើង ហើយគេចាប់យកពួកពេទ្យខ្ញុំចំនួន មួយពេទ្យវរសេនាធំច្រើនដែរ ពេទ្យអនុសេនាធំ ពេទ្យវរៈហ្នឹង រួមគ្នាបាន ៥០-៦០នាក់ គេបញ្ជូនទៅនៅរតនគិរី នៅខែ១២ គេបញ្ជូនកងពល ក្រោយមកឈប់ដាក់១៤ហើយ គេដាក់ថាកងពលលេខ៨០១ ទៅនៅរតនគិរីខ្ញុំនៅនឹងពេទ្យកងពលមានមន្ទីរនៅនឹងវើនសៃ មុនដំបូងទៅដល់នៅបាងលុងសិន នៅបាងលុងបាន១ឆ្នាំកន្លះបានគេដកពេទ្យហ្នឹងទៅដាក់នៅវើនសៃ ឆ្នាំទី១ទៅនៅវើនសៃ ឆ្នាំ១៩៧៧ខ្ញុំនៅត្រើយខាងលិចទន្លេ ៧៨គេដកពីខាងលិចទន្លេសេសានហ្នឹង មកនៅខាងកើតវើនសៃ ។

ដានី៖ លោកពូពេលដែលកងទ័ពកងពល១៤ ចូលមកភ្នំពេញដំបូង យើងចូលមកតាមច្រកណា? ហើយនៅទីកន្លែងណាខ្លះទៅ?

សារឿន៖ ខ្ញុំកាលចូលមកខ្ញុំចូលតាមវត្តស្ទឹងមានជ័យ ខ្ញុំចូលកាត់ពីក្រោយវត្តស្ទឹងមានជ័យមកដើរតាមស្ពានស្ទឹងមានជ័យហ្នឹងឡើងមកបឹងសាឡាង កំលាំងខ្ញុំ បឹងសាឡាង ពេទ្យលោកសង្ឃបុកចូលមកផ្សារដើមគរនៅហ្នឹងបណ្តោយទៅ ។

ដានី៖ ទីតាំងកងពលនៅណា?

សារឿន៖ ទីតាំងកងពលកាលហ្នឹងដូចមិនមានអីប្រាកដទេ មានបញ្ជាការកងពលប៉ុន្មាននាក់នៅក្បែរស្អាតនេះ ។

ដានី៖ ដូចតា០៥, ០៦?

សារឿនៈ បាទ! តា០៥, ០៦ គាត់នៅក្បែរស្អាតនេះ។ ឥឡូវសួរប្រពន្ធខ្ញុំដឹងតា០៥, ០៦នៅណា។ ប្រពន្ធខ្ញុំនៅស្អាតដែរ ជំនាន់៧៥ ។

ប្រពន្ធៈ ទៅមកៗដែរ ។

សារឿនៈ គាត់ចល័តវាលំបាក ។

ប្រពន្ធៈ ដូចអត់មានមន្ទីរកងពលដាក់លាក់ដូចឥឡូវទេកាលហ្នឹង ។

ដានីៈ កាលហ្នឹងដូចថាកំលាំងកងពល១៨ យើងឈរជើងពីត្រឹមណា ដល់ត្រឹមណា? ១៨ក្នុងភ្នំពេញ?

សារឿនៈ ក្នុងភ្នំពេញ?

ដានីៈ បាទ ។

សារឿនៈ មួយវរសេនាតូច វរសេនាធំខ្ញុំឈរជើងពីកែងមកខាងជើងចេះ មកដល់ផ្លូវចូលឃ្លាំងរំសេវមួយកាច់ចេះមកផ្សារដើមគរ មកលិចធ្លាក់បឹងសាឡាង-ពេទ្យលោកសង្ឃ ហើយបានចេញទៅអឺជើង ទៅម្តុំបង្គោលអន្ទង់ក្វាន ទៅបឹងសំយ៉ាប ។

ដានីៈ ហ្នឹងវរសេនាធំផ្សេងទៀត?

សារឿនៈ វរសេនាធំផ្សេងទៀតខ្ញុំក្តាប់អត់បានទេពេលហ្នឹង ដឹងតែវរសេនាធំខ្ញុំនៅប្រកអឺចឹង ។

ដានីៈ ដល់ពេលមុនបែក៧៥ លោកពូអត់ទាន់ធ្វើពេទ្យទេ?

សារឿនៈ ខ្ញុំធ្វើពេទ្យនៅឆ្នាំ៧៣ ពេទ្យកងទ័ព នៅក្នុងកងទ័ពវរ៣៨ខ្ញុំធ្វើពេទ្យហើយ ។

ដានីៈ ពេលហ្នឹងបានទៅរៀនជាមួយលោកតាជួន ជឿន?

សារឿនៈ រៀនជាមួយលោកតាជួន ជឿន បាន៣ខែ ។

ដានីៈ ទៅរៀននៅណាទៅ?

សារឿនៈ ទៅរៀននៅអង្គព្រលឹង ។

ដានីៈ អង្គព្រលឹងនៅ?

សារឿនៈ អង្គព្រលឹងនៅក្នុងវត្តអង្គព្រលឹងហ្នឹង ។

ដានីៈ អង្គព្រលឹងនៅខ្ពក ឬអមលាំង?

សារឿនៈ ខត្តុង្គ ស្រុកខត្តុង្គ កាលហ្នឹងគេមានមន្ទីរពេទ្យមួយនៅអង្គព្រលឹង ខ្ញុំរបួសដេកពេទ្យទៅអង្គភាពគេបញ្ជូនឲ្យរៀន រៀននៅក្នុងពេទ្យហ្នឹងបណ្តោយ រៀនបណ្តើរ ព្យាបាលរបួសខ្លួនឯងបណ្តើរ រៀនពេទ្យបណ្តើរ ។

ដានីៈ ដល់ពេលចូលដល់ទីក្រុងភ្នំពេញ ពេលចូលមកដល់មិនចាប់ផ្តើមជម្លៀសប្រជាជនចេញ?

សារឿនៈ បាទ! ចាប់ផ្តើមជម្លៀស ។

ដានី៖ កាលហ្នឹងយ៉ាងម៉េចដែលលោកពូឃើញទិដ្ឋភាពនៅទីក្រុងភ្នំពេញ ហើយការជម្លៀស ដូចថាម៉េចដែរ? ពេលហ្នឹងជម្លៀសចេញដោយស្ម័គ្រចិត្ត ឬក៏ត្រូវមានបទបញ្ជាថាឲ្យចេញ ឬយ៉ាងម៉េច?

សារឿន៖ កាលនោះពេលចូលមកដល់គេមានបទបញ្ជាឲ្យជម្លៀសប្រជាជនចេញ គេបញ្ជាឲ្យចេញតែម្តងមិនមែនប្រជាជនចង់ចេញទេ គេរៀបចំផែនការការពារក្រុងបានទាល់តែជម្លៀសប្រជាពលរដ្ឋចេញទើបបោសសំអាតខ្មាំងអស់ ទាហានលន់ នល់អីហ្នឹង ទុកប្រជាជនមិនអាច ។

ដានី៖ ការជម្លៀសហ្នឹងបើសិនជាបន្ទុកប្រជាជនវាយ៉ាងម៉េចធំ?

សារឿន៖ ប្រជាជនលំបាកវេទនាណាស់ ខ្ញុំកងទ័ពក៏ឃើញកងទ័ពលំបាកវេទនាដែរ មានចាស់ជរាខ្លះវ្ញញឡាន ខ្លះសែងគ្នាចេញផុតពីក្រុងទៅលំបាកវេទនាតាមផ្លូវម៉េចខ្ញុំមិនដឹងទេ តែពេលកំពុងតែចេញពីក្រុងគឺវេទនា ខ្ញុំក៏ដឹងដែរ បើសិនខ្ញុំមិនមែនជាអ្នកដឹកនាំ តែតាមបទបញ្ជាមិនដឹងធ្វើម៉េច គេរៀបចំអីចឹង បេះតែដេញឲ្យចេញទៅ ទិសដៅយុទ្ធសាស្ត្រគេ គឺណែនាំដេញប្រជាជនចេញឲ្យអស់ ដើម្បីបោសសំអាតក្រុងឲ្យអស់ ។

ដានី៖ បោសសំអាតអីគេ?

សារឿន៖ បោសសំអាតទាហានរបស់លន់ នល់ ក្រែងលោមានសេសសល់ លាក់អាវុធ ទៅធ្វើសកម្មភាពវ៉ៃតបតមកកងទ័ពខ្មែរក្រហម ធ្វើបដិវត្តន៍វិញ ។

ដានី៖ កាលហ្នឹងដូចថាលោកពូប្រជុំ ទទួលបញ្ជាពីខាងណា ដែលកាលហ្នឹងយើងត្រូវតែបោសសំអាតទាហានចេញ ហើយយើងត្រូវដេញប្រជាជនចេញ?

សារឿន៖ កាលហ្នឹងខ្ញុំបញ្ជាតាមប្រធានវរៈ ។ ប្រធានវរៈខ្ញុំឈ្មោះតាញ៉ាៗ គាត់ចុះមកណែនាំឲ្យតាមកងធំទាំងមូលប្រមែលប្រមូលប្រជាជនឲ្យចេញជាបណ្តោះអាសន្នគេកុហកអីចឹង បណ្តោះអាសន្ន ហើយគាត់ចេញទៅ ខាងក្រៅទីក្រុងទៀតខ្ញុំលែងដឹងហើយ មិនដឹងទៅដល់ណាដល់ណីទេ តែថ្ងៃជម្លៀសចេញគឺខ្ញុំនៅជាមួយប្រជាពលរដ្ឋទាំងអស់ ពេលចូលមកដល់ហើយស្អែក ខានស្អែកឡើងគាត់ចេញបន្តៗគ្នា ណាស្រុកណាទៅស្រុកហ្នឹង ឬក៏ម៉េចខ្ញុំមិនយល់ដែរ ។

ដានី៖ យើងទទួលមកបន្តៗទៀត យើងអត់បានប្រជុំជាមួយឋានៈកងពលទេ?

សារឿន៖ អត់ទេ អត់ដែលទេ ។

ដានី៖ អីចឹងប្រជាជនប៉ុន្មានថ្ងៃដែលចេញអស់ពីទីក្រុងភ្នំពេញ?

សារឿន៖ ប្រជាជននៅក្រុងភ្នំពេញចេញខ្ទង់៣ថ្ងៃ ។

ដានី៖ ៣ថ្ងៃចេញអស់?

សារឿន៖ បាទ! ៣ថ្ងៃចេញអស់ ។

ដានី៖ ប្រជាជនចេញអស់ទៅ យ៉ាងម៉េចទៀតទៅ? យើងបោសសំអាតទាហានម៉េចទៅ? ទាហានមាននៅក្នុងហ្នឹងទៀតអត់?

សារឿន៖ ពេលប្រជាជនគាត់ចេញអស់ទៅ បាន៩ថ្ងៃនៅផ្ទះអាណាមិកមួយ ឥឡូវគេដាក់ស្អីទេនៅជាប់នឹងផ្សារដើមគរ ផ្ទះហ្នឹងចាស់ទេ នៅសព្វថ្ងៃក៏នៅចាស់ដែរ គេហៅផ្ទះអណាមិកក្នុងហ្នឹងកន្លែងពេទ្យ ទៅដល់ឃើញនៅកែងចេញពីផ្សារដើមគរ អាខាងជើងគេចេះ មានកែងជ្រុងហ្នឹងគឺមានផ្ទះកន្លែងបាញ់គ្នា បាញ់គ្នាជាមួយទាហាន ពួកខ្ញុំដេកក្នុងផ្សារ ។

ដានី៖ នៅកន្លែងកែងផ្សារដើមគរហ្នឹង?

សារឿន៖ ខ្ញុំនៅរោងកុនបេនឡា ។

ដានី៖ រួចបាញ់ជាមួយទាហាននៅកន្លែងណា?

សារឿន៖ វាបាញ់ទាហាននៅផ្ទះ វាបាញ់ចេញពីលើផ្ទះមក នៅសេសសល់អីចឹង ។

ដានី៖ ទាហានវាបាញ់មក?

សារឿន៖ ទាហានលន់ នល់បាញ់ចេញមក ហើយចាប់ផ្តើមផ្ទុះអាវុធទៅ ស្អែកឡើងបានចាប់បានទាហាន៦នាក់ ខាងលើគេយកទៅខ្ញុំក៏មិនដឹងគេយកទៅណាទៀតក៏ខ្ញុំមិនដឹងដែរ ចាប់បានបញ្ជូនទៅឲ្យគេ គ្នាដាក់អាវុធសុំចុះចាញ់ ។

ដានី៖ ក្រុមរបស់លោកពូអ្នកចាប់បានតែម្តង ឬក៏?

សារឿន៖ ក្រុមរបស់ពួកខ្ញុំអ្នកចាប់បាន តែចាប់បានប្រធានវរៈគេនៅប្រយុទ្ធជាមួយគ្នាគេយកទៅ ។

ដានី៖ ចាប់បានដោយសារខាងទាហានគេលើកទង់ស ឲ្យយើងចាប់?

សារឿន៖ លើកទង់ស ក្រោយគេចេញអស់៥-៦ថ្ងៃបានផ្ទុះអាវុធ គាត់នៅសំងំក្នុងផ្ទះហ្នឹង អីចឹងបាញ់គ្នាតែមួយប្រាវ ព្រលឹមឡើងគេចូលឆែកឆេរគាត់ទំលាក់អាវុធលើកដៃ អស់គ្រាប់ ។

ដានី៖ ហើយគេយកទៅណាវិញ?

សារឿន៖ គេយកទៅកន្លែងវរៈនៅផ្ទះខាងកើតហ្នឹងទៅ ខ្ញុំក៏នៅរោងកុនហ្នឹងទៀត ។

ដានី៖ ក្រៅពីព្រឹត្តិការណ៍ហ្នឹងមានអីទៀតដែលអត់?

សារឿន៖ អត់មានអីទៀតទេ មានតែចាប់ផ្តើមរៀបចំបោសសំអាតផ្ទះសំបែងដែលអស់ប្រជាពលរដ្ឋហ្នឹង បោសសំអាតផ្ទះសំបែងដែលកំទិចសំរាម យកឡានទឹកទៅចោលបឹងទំពន់នោះ ។

ដានី៖ លោកពូ ៦នាក់ហ្នឹងយើងដឹងសមាសភាពគាត់ជាទាហានធម្មតា ឬជាមេទាហាន ជាអីដែរ?

សារឿន៖ មិនដឹងអីដែរ គ្រាន់តែស្លៀកពាក់អាវទាហាន ខ្ញុំអត់បានសាកសួរ ។

ដានី៖ អត់មានលឺគេថាគាត់ជាអ្នកនេះ អ្នកនោះ?

សារឿន៖ អត់មានបានលឺ គ្រាន់តែឈ្មោះក៏មិនដែលបានដឹងដែរ គ្រាន់តែឃើញបញ្ជូនឲ្យគេទៅ ។

ដានី៖ ដល់ពេលបញ្ជូនហើយក្រោយមកយើងបោសសំអាតតាមផ្ទះ?

សារឿន៖ បោសសំអាតតាមផ្ទះ ថែរក្សាតាមផ្ទះនៅ បន្ទប់ទឹកដែលមានសំរាម ធម្មតាកង់ទ័ពពេលហ្នឹងចូលទៅរុះរើចេះតែរកមើលអីហូប អីចឹងវាសំរាមពាសវាល ពាសកាលចេះតែដើរប្រមែលប្រមូល លើកដាក់ឡានត្រូវចោលៗទៅ ។

ដានី៖ យើងមានរបស់របរហូបច្រើនទេកាលហ្នឹង?

សារឿន៖ មិនខ្វះអីមានតាំ ។

ដានី៖ តាមផ្ទះ?

សារឿន៖ តាមផ្ទះអត់ខ្វះទេ មាន់ ទា ជ្រូក គោ នៅភ្នំពេញគ្មានគោប៉ុន្មានទេ មានតែជ្រូក មាន់ ទា

ដានី៖ ហើយនឹងរបស់នៅក្នុងផ្ទះគេ ។

សារឿន៖ របស់តាមផ្ទះ ។

ដានី៖ របស់ហ្នឹងគេមានផែនការយើងប្រមូលដាក់ម៉ុំៗ?

សារឿន៖ អត់ទេ គេអត់ប្រមូលទេ គេចោលតែម្តង សម្ភារៈ ឧបករណ៍ គេអត់យកទេ ព្រោះកន្លែងណាក៏មានដែរ ក្នុងតំបន់ដែលគេកាន់កាប់ហ្នឹង ។

ដានី៖ របស់មានតម្លៃដូចជា?

សារឿន៖ របស់មានតម្លៃមាស ពេជ្រ អីដូចមិនសូវឃើញមាន បងប្អូនគាត់យកតាមខ្លួនមានខ្លះក្មេចចិញ្ចៀនអីតិចតួច នាឡិកា បងប្អូនយកពាក់ទៅ អត់មានរបស់មានតម្លៃអីទេ បងប្អូនគាត់យកទៅតាមជាប់ខ្លួន ។

ដានី៖ យើងបោសសំអាត យើងប្រមែលប្រមូលរយៈពេលប៉ុន្មានទៅ?

សារឿន៖ រយៈពេលដូចយូរដែរ អាមុនរៀបទៅ អាក្រោយមករើទៅ វារុះរើ ខ្ញុំរៀបចំមួយជួរផ្ទះអីចឹងទៅ កងផ្សេងដែលគេសុំចូលមករកសហករណ៍អីគេមកក្រោយ គេមករើយកទៅគេត្រូវការអីយកហ្នឹងទៅ មកវិលរៀបទៀតទៅ រៀបត្រឡប់ទៅត្រឡប់មក ។

ដានី៖ ចន្លោះពីខែ៤-១១ យើងនៅក្នុងហ្នឹងយើងធ្វើការតែប៉ុណ្ណឹងទេ?

សារឿន៖ បាទ! ខ្ញុំធ្វើការតែប៉ុណ្ណឹង ខ្ញុំមិនសូវជាអ្នកបោសសំអាតអីប៉ុន្មានទេ ខ្ញុំដើរព្យាបាល ។

ដានី៖ ដើរព្យាបាល?

សារឿនៈ ដើរព្យាបាលគេ ទី១ខ្ញុំព្យាបាលនៅជុំវិញផ្សារដើមគរ បឹងសាឡាង និងឃ្លាំងរំសៀវ ហើយទៅព្យាបាលមួយកងទៀតនៅស្ទឹងមានជ័យ នៅភូមិឫស្សី គេនៅយាមប៉ុស្តិ៍វិទ្យុផង នៅធ្វើស្រែនឹងផង ។

ដានីៈ បន្ទាប់ពីប្រជាជនដែលជម្លៀសអស់ ក្រោយមកព្រឹត្តិការណ៍ដែលចាប់បានទាហាន៦នាក់ហ្នឹងហើយ ក្រោយមកមានប្រជាជននៅក្នុងផ្ទះ ឬមានស្លាប់?

សារឿនៈ អត់មានទេ អត់មានសោះ ពួកគាត់ទៅអស់ខ្លួនគាត់ ពួកគាត់ភ័យខ្លាច គាត់ទៅដោយអត់មានរុញរាទេ ។

ដានីៈ លោកពូមួយទៀត លោកពូមានប្រសាសន៍ថាដល់ខែ១១ ខែ១២ហ្នឹងយើងប្តូរឈ្មោះកងពលអីលោកពូ?

សារឿនៈ បាទ ។

ដានីៈ ការដែរប្តូរឈ្មោះកងពលហ្នឹងមានការប្រជុំអី ដូរអីត្រឹមត្រូវដែលឬយ៉ាំងម៉េច?

សារឿនៈ ចំណុចហ្នឹងមួយខ្ញុំអត់ដឹងទេ ដឹងតែគេប្រកាសឈ្មោះកងពលមកបណ្តោយ រឿងត្រង់ពិភាក្សាយ៉ាំងម៉េចៗខ្ញុំអត់ដឹងទេ ។

ដានីៈ គេប្រកាសនៅណា?

សារឿនៈ គេប្រកាសកងពលលេខ៨០១ ប្រកាសនៅឥសាន ប្រកាសយើងនៅបាងលុង គេរៀបវរសេនាធំហើយ គេរៀបពួកខ្ញុំពេទ្យមួយវរៈហើយ គេថាកងពលហ្នឹងលេខ៨០១ ក៏ថាតាមគេលេខ៨០១ ឈប់ថា១៨ទៅ គ្រាន់តែគេអ្នកដឹកនាំធំៗ ត្រឹមវរៈគេដឹងម៉េចមិនដឹងតែសំរាប់ខ្ញុំបុគ្គលិកពេទ្យគេមិនសួរយកប្រើការទេ ។

ដានីៈ ទៅដល់រតនគិរីហើយបានគេប្រកាសថាកងពលហ្នឹង កងពល៨០១?

សារឿនៈ បាទ! ជួនពេលនោះគេប្រកាសកងពលហ្នឹង៨០១ គេដាក់វរសេនាតូចពេទ្យរបស់ខ្ញុំគេដាក់វរសេនាតូច៨០៥ ពេទ្យហ្នឹងមានគ្នា៣០០នាក់ ។

ដានីៈ វរសេនាតូច៨០៥ហ្នឹងពេទ្យ?

សារឿនៈ ពេទ្យកងពល៨០១ ។

ដានីៈ អត់មានចំណុះឲ្យវរសេនាធំណាទេ?

សារឿនៈ អត់ទេ ។

ដានីៈ ឯករាជ្យតែម្តង?

សារឿនៈ បាទ! ឯករាជ្យ ។

ដានីៈ ៨០១ កាលនោះមានប៉ុន្មានវរសេនាធំទៅ?

សារឿនៈ មាន៣វរសេនាធំ ។

ដានីៈ វរសេនាធំលេខប៉ុន្មានខ្លះ?

សារឿនៈ វរសេនាធំលេខ៨១, វរសេនាធំ៨២ និងវរសេនាធំ៨៣ ។ ៨១នៅអូរយ៉ាដាវ បរកែវ ហ្នឹងនៅច្រកហ្នឹង ។

ដានីៈ អូរយ៉ាដាវ-បរកែវ ឬក៏បរកែវទេ?

សារឿនៈ បរកែវ ។

ដានីៈ បរកែវ មិនមែនអូរយ៉ាដាវទេ?

សារឿនៈ បាទ! បរកែវ ។ អូរយ៉ាដាវ-បរកែវ ច្រកតែមួយទេ ក្បែរគ្នាហ្នឹងទេ ។

ដានីៈ នៅទាំងពីរហ្នឹង ។ ហើយ?

សារឿនៈ ហើយវរសេនាធំ៨៣ នៅអូរជំបូក ។

ដានីៈ ៨៣នៅអូរជំបូក ។

បូលីៈ កន្ទុយនាគ?

សារឿនៈ បាទ! កន្ទុយនាគ អូរជំបូកហើយកន្ទុយនាគ តាមទន្លេសេសាន ។

ដានីៈ នៅតែមួយកន្លែងហ្នឹងទេ?

សារឿនៈ នៅតែមួយកន្លែងហ្នឹងទេ វរសេនាធំ៨២នៅយើងសៀមប៉ាង ជុំក្រឡយើងព្រំដែនឡាវ ខេត្តស្ទឹងត្រែងសព្វថ្ងៃ ។

ដានីៈ ដល់ពេលមន្ទីរកងពលនៅ?

សារឿនៈ មន្ទីរកងពលមួយឆ្នាំដំបូងនៅបាងលុងនៅខាងកើតបាងលុងជាប់គ្នា ម្ខាងផ្លូវម្នាក់ ។

ដានីៈ ក្រោយមក?

សារឿនៈ ក្រោយមកផ្លាស់ទៅនៅវើនសៃ ។

ដានីៈ តែ២កន្លែងហ្នឹងទេ?

សារឿនៈ ២កន្លែងហ្នឹង អត់មានកន្លែងណាទៀតទេ រហូតដល់៧៩ ។

ដានីៈ កាលហ្នឹងគណៈកងពលនៅ០៥ដដែល?

សារឿនៈ បាទ! នៅ០៥ គាត់ធ្វើប្រធានដដែល ។

ដានីៈ បន្ទាប់ៗគាត់?

សារឿនៈ បន្ទាប់គាត់មានដែរ តែឥឡូវងាប់អស់បាត់ហើយមិនដឹង វាចាប់ខ្លះអីខ្លះ ។

ដានីៈ កាលជំនាន់ហ្នឹងមានពីណាខ្លះ?

សារឿនៈ កាលជំនាន់ហ្នឹងមានតា០៥, មានតាសុន, មានអ៊ីវ៉ែននេះ ។

ដានី៖ វ៉ែន?

សារឿន៖ អ៊ីវ៉ែន នៅអន្លង់វែង គាត់ក៏នៅក្នុងសមាជិកដែរ ក្រោយមកគេដកទៅកាន់ភូមិភាគឥសាន វ៉ែន នៅថ្នាក់នេះ។

ដានី៖ អ៊ុង វ៉ែន ហ្នឹង?

សារឿន៖ បាទ! អ៊ុង វ៉ែន ហ្នឹង។

ដានី៖ គាត់ក្រុមប្រឹក្សា?

សារឿន៖ បាទ! គាត់ប្រឹក្សា។

ដានី៖ គេដកឲ្យគាត់មកនៅខាងតំបន់វិញ?

សារឿន៖ បាទ! គេដកគាត់ឲ្យទៅកាន់ភូមិភាគ តែក្រោយមកគេមកកាន់សេនាធិការភ្នំពេញ មិនដឹងម៉េចទៀត។

ដានី៖ អត់អីៗ ចាំខ្ញុំជួបគាត់។

សារឿន៖ សួរគាត់ទៅព្រោះគាត់ធ្លាប់បានទៅចិនសម័យ ទៅជិះយន្តហោះគាត់និយាយ ខ្ញុំមិនមែនដឹងប្រវត្តិគាត់។

ដានី៖ អីចឹងគណៈកងពល៨០១ តា០៥, តាសារឿន, តាសុន គាត់ឈ្មោះពេញ?

សារឿន៖ ឈ្មោះពេញអីចឹងតែម្តង?

ដានី៖ តាសុន ឈ្មោះអីទៅ? ឈ្មោះពេញគាត់?

សារឿន៖ ស៊ីគេសុន ទេ ពិបាកចាំដែរ។

ដានី៖ នេះក្រោយទេ បើយើងទៅដំបូង?

សារឿន៖ នេះក្រោយហើយ។

ដានី៖ ទៅដំបូងពីឆ្នាំ៧៥ ពីខែ១១-១២?

សារឿន៖ មានតែតាសារឿន មួយទេទៅដំបូង ពីមុនពីរនាក់តាសានៗ ដល់តាសាន គេដកគាត់ទៅកាន់កងពល៩២០នៅមណ្ឌលគិរី នៅសល់តែគាត់មួយៗ ក្រោយមកតាចើម បន្ថែមៗ

ដានី៖ វរៈ៨១ ពីណាគេ? វរសេនាធំ៨១?

សារឿន៖ តាម៉ៅ ធ្លាប់លឺហើយនៅនោះ អ្នកនៅសំឡូតសព្វថ្ងៃៗ

ដានី៖ ឥឡូវគាត់នៅសំឡូត?

សារឿន៖ បាទ! គាត់នៅសំឡូតៗ

ដានី៖ ឥឡូវគាត់នៅរស់?

សារឿន៖ នៅតាំៗ

ដានី៖ ប្រពន្ធគាត់ឈ្មោះអីទៅ?

សារឿន៖ ឈ្មោះជ្រើន។

ដានី៖ សំឡូតនៅកន្លែងណា? គាត់នៅឃុំណា?

សារឿន៖ សំឡូត បាត់ដំបង។

ដានី៖ បាទ! ខ្ញុំដឹង ស្រុកសំឡូត ខេត្តបាត់ដំបង តែគាត់នៅ?

សារឿន៖ ខ្ញុំអត់ស្គាល់ អត់ចាំទេ ដឹងតែគាត់នៅខាងហ្នឹង មិនចាំទេ ភូមិ-ឃុំទេ។

ដានី៖ ឈ្មោះម៉ៅ តែមុនម៉ៅ ហ្នឹងមានពីណាទៀតទេ?

សារឿន៖ មុនម៉ៅ អត់មានទេ។

ដានី៖ ម៉ៅ ហ្នឹងគាត់កាន់វរសេនាធំរហូត ឬយ៉ាងម៉េច?

សារឿន៖ គាត់កាន់វរសេនាធំហ្នឹងរហូត។

ដានី៖ បន្ទាប់ពីម៉ៅ ហ្នឹងមានពីណាទៀតអត់?

សារឿន៖ មុន ម៉ៅ ហ្នឹងអត់មានទេ។

ដានី៖ ម៉ៅ ហ្នឹងគាត់កាន់វរសេនាធំរហូត ឬយ៉ាងម៉េច?

សារឿន៖ បាទ! គាត់កាន់វរសេនាធំរហូត។

ដានី៖ បន្ទាប់ពីម៉ៅ ពីណាទៀតដែលអត់?

សារឿន៖ រងខ្ញុំអត់ស្គាល់។

ដានី៖ ចុះ៨២?

សារឿន៖ ៨២ តាស៊ិន។

ដានី៖ គាត់នៅណាឥឡូវ?

សារឿន៖ គាត់ស្លាប់បាត់ហើយ ស្លាប់សម័យនោះគេចាប់ទៅដាក់គុក ដាក់ច្រវ៉ាក់អីដែរ។

ដានី៖ ហើយពីណាឡើងបន្ទាប់ពីគាត់?

សារឿន៖ ឡើងបន្ទាប់ពីគាត់អត់ចាំទេ។

ដានី៖ ហើយចុះ៨៣?

សារឿន៖ ៨៣ ពីដំបូងតាសុន ហ្នឹងហើយ តែក្រោយមកមិនដឹងគេដាក់ពីណា ដកតាសុន ឡើងមក កងពលមិនដឹងដាក់ពីណា អត់ចាំ។

ដានី៖ អត់ចាំទៀត?

សារឿន៖ អត់ចាំអស់។

ដានី៖ តាធិន, តាឡឺ?

សារឿនៈ តាធិន, តាឡី កាលហ្នឹងគាត់ ខ្ញុំមិនដឹងជានៅកងណាដែរ តែតាធិន គេដកគាត់ទៅកាន់តំបន់ ដកពីកងទ័ពទៅកាន់តំបន់ ។

ដានីៈ តំបន់នៅណាទៅ?

សារឿនៈ តំបន់នៅវ៉ើនសៃ ដកគាត់ទៅរតនគិរី ដកគាត់ពីកងពលទៅកាន់តំបន់ ។ តាធិន មួយទៀត រងបង០៥ ។

ដានីៈ តាធិន មួយទៀត?

សារឿនៈ បាទ! តាធិន រង ។

ដានីៈ តាធិន គាត់នៅតាំងពីអង្កាល់មក?

សារឿនៈ នៅអង្គភាពហ្នឹងយូរហើយ តាំងពីនៅកងពល១៨ម៉្លេះ ។

ដានីៈ ចុះតាឡី?

សារឿនៈ តាឡី អត់ច្បាស់លាស់ ។

ដានីៈ អីចឹងលោកពូនៅក្នុងវរៈ៨០៥?

សារឿនៈ បាទ! ខ្ញុំនៅវរៈ៨០៥ ។

ដានីៈ កងពល៨០១ មានវរៈឯករាជ្យប៉ុន្មានទៅ? វរសេនាតូចឯករាជ្យ?

សារឿនៈ វរៈឯករាជ្យមានវរៈ៨០៥ មួយ, វរៈ៨០៦ មួយ ។

ដានីៈ ៨០៦ហ្នឹងវរៈអីគេ?

សារឿនៈ ហ្នឹងវរៈដឹកជញ្ជូន ។ ហើយវរៈ០៤នោះស្ត្រី កងស្រី ។

ដានីៈ វរសេនាតូច០៤?

សារឿនៈ បាទ! វរសេនាតូច០៤ កងនារី វរៈសេនាតូច០៣នោះកងកាំភ្លើងធំ ។

ដានីៈ ប៉ុណ្ណឹងទេ?

សារឿនៈ ប៉ុណ្ណឹង អ៊ូ! មួយទៀត នៅ៨០២មួយទៀត កងពិសេស កងពល ។

ដានីៈ វរសេនាតូចដែរ?

សារឿនៈ វរសេនាតូច៨០២ ហ្នឹងកងពិសេសរបស់កងពល ។

ដានីៈ ចុះ០៤, ០៣ ហ្នឹង៨០៤, ៨០៣ ឬយ៉ាងម៉េច?

សារឿនៈ ៨០៣ ។

ដានីៈ ៨០៣?

សារឿនៈ ៨០៣ ។

ដានី៖ ៨០៤ កងនារី, ៨០៣ កងកាំភ្លើងធំ, ៨០៥ ពេទ្យ, ៨០៦ ដឹកជញ្ជូន ដល់៨០២ កងពិសេស ។

សារឿន៖ កងពិសេសរបស់កងពល ។

ដានី៖ ប្រធាន៨០២ពីណាគេ?

សារឿន៖ តាឡូច ។

ដានី៖ គាត់នៅទេសព្វថ្ងៃ?

សារឿន៖ កាលហ្នឹងមិនដឹងទៅណាទេបង សម័យ៣ឆ្នាំ គេចេះតែហៅគាត់ទៅរៀនភ្នំពេញ ទៅៗបាត់ទៅ ។

ដានី៖ ខាងកងកាំភ្លើងធំ?

សារឿន៖ កងកាំភ្លើងធំពីមុនតាហាន ។

ដានី៖ ក្រោយមក?

សារឿន៖ ក្រោយមក ជា កែវ យើងនេះ ។

ដានី៖ ជា កែវ គាត់?

សារឿន៖ គាត់រង ។ រងតាហាន ។

ដានី៖ ដល់ពេលបាត់ តាហាន ទៅ, ជា កែវ គាត់ឡើង ។

សារឿន៖ ជា កែវ គាត់ឡើង?

ដានី៖ ជា កែវ គាត់ខ្មែរ ឬក៏ជនជាតិ?

សារឿន៖ ខ្មែរ ។

ដានី៖ ស្រុកកំណើតគាត់នៅណា?

សារឿន៖ ស្រុកកំណើតខ្ញុំអត់ដឹងទេ គ្រាន់តែដឹងថានៅត្បូងគពង ។

ដានី៖ វរៈនារី៨០៤នេះពីណាគេធ្វើប្រធាន?

សារឿន៖ យាយរឿន ។

ដានី៖ យាយរឿន ប្ដីគាត់ពីណាគេ?

សារឿន៖ ប្ដីគាត់មិនដឹងពីណា កែវ សារឿន មិនដឹង ភ្លេចហើយ ។

ដានី៖ កែវ សារឿន កាលនោះគាត់ធ្វើអី?

សារឿន៖ កាលនោះគាត់ធ្វើប្រធានវរសេនាធំដែរ តែគាត់ឡើងមករងកងពល ។

ដានី៖ គាត់វរសេនាធំមួយណា ក្នុង៣ហ្នឹង?

សារឿន៖ គាត់នៅ៨២ ។

ដានី៖ នៅជាមួយតាស៊ិន?

សារឿន៖ ជាមួយតាស៊ិន។

ដានី៖ គាត់ធំជាងតាស៊ិន ឬតូចជាងតាស៊ិន?

សារឿន៖ កាលហ្នឹងមិនដឹងអ្នកណាធំ អ្នកណាតូចទេ តែ២នាក់ហ្នឹងនៅក្នុង៨២។

ដានី៖ អីចឹងប្រធានកងនារី ឈ្មោះយាយរឿន?

សារឿន៖ យាយរឿន។

ដានី៖ តែប្ដីគាត់អត់ដឹងពីណា?

សារឿន៖ ប្ដីគាត់អត់ដឹងពីណា។

ដានី៖ ចុះវរសេនាតូចរបស់លោកពូខាងពេទ្យនេះ?

សារឿន៖ របស់ខ្ញុំពីមុន មកដំបូង ឡាយ សារីម។

ដានី៖ ថាគេចាប់ដែលហ្នឹង?

សារឿន៖ គេចាប់ដែរហ្នឹង ក្រោយមកឡើង យ៉ោក ជើន។

ដានី៖ យ៉ោក ជើន!

សារឿន៖ យ៉ោក ជើន ក្រោយមក។

ដានី៖ កាលហ្នឹងលោកពូមានតួនាទីអីដែរ?

សារឿន៖ កាលនោះខ្ញុំនៅក្នុងពេទ្យ ខ្ញុំធ្វើប្រធានកងតូច ពេទ្យហ្នឹង។

ដានី៖ វរៈសេនាតូចដឹកជញ្ជូន?

សារឿន៖ វរសេនាតូចដឹកជញ្ជូនឈ្មោះ មុន។

ដានី៖ ដល់ពេលក្រោយមកគាត់កាន់កងពលដែរ?

សារឿន៖ អត់ទេ មុន ហ្នឹងគាត់នៅតែកងដឹកជញ្ជូន សព្វថ្ងៃនេះទៅស្រុកស្រែអស់ មិនដឹងម៉េចម៉ា។

ដានី៖ អីចឹងក្នុងចំណោមនេះ ម៉ៅ គាត់នៅរស់?

សារឿន៖ បាទ! តាម៉ៅ គាត់នៅ។

ដានី៖ តាសុន?

សារឿន៖ តាសុន ស្លាប់បាត់ហើយ។

ដានី៖ យ៉ោក ជើន?

សារឿន៖ ស្លាប់ហើយ។

ដានី៖ យាយរឿន?

សារឿន៖ ស្លាប់ហើយ។

ដានី៖ ឡូច?

សារឿន៖ ឡូច ហ្នឹងគេចាប់បាត់ ។

ដានី៖ ដា កែវ គាត់នៅព្រះវិហារ?

សារឿន៖ ដា កែវ គាត់នៅប្រាសាទព្រះវិហារ ។

ដានី៖ ហាន បាត់ដែរ?

សារឿន៖ ហាន គេចាប់ដែរ ចាប់សម័យប៉ុលពត ហ្នឹង ។

ដានី៖ លោកពូកាលនៅរតនគិរីយ៉ាងម៉េចដែរកងទ័ពដូចជា ពេលហ្នឹងសភាពការណ៍យ៉ាងម៉េច កងទ័ពនៅតាមព្រំដែន?

សារឿន៖ កងទ័ពតាមព្រំដែនខ្ញុំក្តាប់អត់បានទេ ព្រោះខ្ញុំពេទ្យនៅក្រោយ នៅមន្ទីរនៅក្រោយ ឆ្ងាយពីសមរភូមិរាប់រយគីឡូ អីចឹងខ្ញុំដឹងតែកិច្ចការងារខ្ញុំព្យាបាលអ្នកជំងឺ ដាំបន្លែឲ្យអ្នកជំងឺហូបតែប៉ុណ្ណឹងទេ ។ ដាក់វេនគ្នាព្យាបាល ដាំបន្លែ ធ្វើពលកម្មប៉ុណ្ណឹងឯង រួចពីការងារព្យាបាលខ្ញុំទៅពលកម្ម កន្លះខែក្រោយមកដូរគ្នាមកព្យាបាលម្តង ខ្ញុំដឹងតែប៉ុណ្ណឹង ។

ដានី៖ ពេទ្យរបស់លោកពូនៅមន្ទីរជាមួយកងពល?

សារឿន៖ បាទ! នៅជាមួយមន្ទីរកងពល ។

ដានី៖ តាវ៉ែន ដំបូងគាត់នៅវរសេនាធំដែលតាំ?

សារឿន៖ តាវ៉ែន តាមដឹងគាត់នៅ៨២ ។

ដានី៖ នៅ៨២ដែរ?

សារឿន៖ បាទ! ៨២ ។

ដានី៖ ៨២ ឡើងមកកងពលបាន ។

សារឿន៖ មិនដឹងបានប៉ុន្មានទេ គេដូរគាត់ចេះតែឡើងទៅ ។

ដានី៖ គាត់ឡើងទៅភូមិភាគវិញ?

សារឿន៖ បាទ! គាត់ចេះតែឡើងថារដភូមិភាគឥសាន ក្រោយមកគេដកគាត់ភ្នំពេញទៀត មិនដឹងម៉េចទៀត ។

ដានី៖ គេដកគាត់មកសេនាធិការ?

សារឿន៖ មកសេនាធិការ ។

ដានី៖ លោកពូកាលហ្នឹងកងទ័ពភាគច្រើនឈឺអីទៅ?

សារឿនៈ ភាគច្រើនគ្រុនសណ្ដំ គ្រុនចាញ់ ខ្ញុំនៅបាងលុងមួយឆ្នាំដាង សតិដែលខ្ញុំក្ដាប់ងាប់អស់ ៧៦នាក់ ។ អ្នកជំងឺដែលយើងឡើងពីភ្នំពេញមក រតនគិរីចាញ់ណាស់ ភាគច្រើនសណ្ដំ ឡើងស្មេះ ភាគច្រើនអ្នករស់ អ្នកបូមស្មេះតាមបំពង់កនេះ១០រស់បាន៥ ។

ដានីៈ ភាគច្រើនតែគ្រុនសណ្ដំគឺស្លាប់?

សារឿនៈ គ្រុនសណ្ដំ គ្រុនពោះវៀន ។ តែសណ្ដំឡើងស្មេះកក ។

ដានីៈ ហើយកងទ័ពកាលហ្នឹង យើងដូចជាផ្គត់ផ្គង់ជីវភាព យើងស៊ុយតិទៀន ឬមានជំនួយអី មក?

សារឿនៈ កងទ័ពកាលហ្នឹង តាមខ្ញុំដឹងបើមន្ទីរពេទ្យខ្ញុំនិយាយកំរិត កងទ័ពគេបើកផ្ដល់ឲ្យ ផ្ញើស្រែខ្លួន ឯងផ្សំខ្លះទៅ ហើយគេបើកផ្ដល់បំពេញ ព្រោះកងទ័ពការពារព្រំដែន គេឧបត្ថម្ភ ។ តែពួក មន្ទីរពេទ្យខ្ញុំគេឧបត្ថម្ភពេញទំហឹងតែម្ដង គេឲ្យរបបហូបមួយថ្ងៃ៣ពេល អ្នកជំងឺចេញចូល អត់ទៀងទាត់ អីចឹងវាអត់មានអីកំណត់ទេ ។

ដានីៈ លោកពូស្គាល់លោកពូ ឆោម សែ ទេ?

សារឿនៈ ឆោម សែ?

ដានីៈ ឆោម សែ គាត់ពិការភ្នែកមួយចំហៀង ។

សារឿនៈ ប្រពន្ធគាត់ស្លាប់ហ្នឹង?

ដានីៈ ប្រពន្ធគាត់ស្លាប់ ។

សារឿនៈ តាសែ គាត់មន្ទីរ០៥ ខ្ញុំស្គាល់គាត់តែអត់ស្គាល់ប្រវត្តិ សាវតារច្បាស់ទេ ។

បូលីៈ ស្លាប់ពីអន្លង់ប្រពន្ធ?

សារឿនៈ ប្រពន្ធគាត់ក្រុមប្រឹក្សាឃុំលំទង ស្លាប់ហើយ មិនដឹងគាត់នៅយកប្រពន្ធទៀតមិនដឹង ។

ដានីៈ ទើបតែស្លាប់ដែរ?

សារឿនៈ ប្រពន្ធគាត់ឈ្មោះ ភាព នៅអន្លង់ភាពជាមួយប្រពន្ធខ្ញុំ ។

ដានីៈ ឥឡូវគាត់យកប្រពន្ធទៀតហើយអីចឹង?

សារឿនៈ អត់ដឹង ។

ដានីៈ លោកពូ គឹម នាយករដ្ឋបាល មានស្គាល់គាត់អត់ពេលហ្នឹង?

សារឿនៈ នាយករដ្ឋបាលពេលនោះឈ្មោះ តាឆាង ខ្ញុំស្គាល់ដែរ ។

ដានីៈ ឈ្មោះ តាឆាង?

សារឿនៈ គាត់នៅមន្ទីរ០៥ កាន់តែអូ ដល់ក្រោយមកមានបញ្ហាអី ឬអត់មានទេ គេដកគាត់ទៅ យាមគុកនៅបាងលុង បែកគ្នាទៅ ។

ដានី: គាត់ប្រាប់ដែល គាត់ថាគាត់នៅកន្លែងគុកបាងលុង ។

សារឿន: តែមិនដឹងគាត់ធ្វើអីខ្ញុំមិនដឹង ។

ដានី: កាលហ្នឹងគាត់ឈ្មោះ តាឆាង?

សារឿន: ឈ្មោះឆាង តែក្រោយមក មកឡើងនៅភ្នំដងរែកនេះ ទន្លេល្មោ មុំ៣ យើងហ្នឹង ប៉ុល ពត ត្រូវការអ្នកវប្បធម៌ចាប់ពីថ្នាក់ទី៧ឡើង យកទៅកន្លែងប៉ុលពត គេត្រូវដកគាត់ទៅមន្ទីរ ប៉ុល ពតនៅកោះកុង ។

ដានី: កាលហ្នឹងនៅមន្ទីរកងពលមានកន្លែងសន្តិសុខដែរ?

សារឿន: មានដែរ មានយាមកាមធម្មតា ។

ដានី: សន្តិសុខជាវរសេនាតូច ជាស្អីដែល ឬអត់ទេ?

សារឿន: សន្តិសុខតាមម្ចាស់ការ តាមអង្គភាពវរសេនាតូច ។ ឧទាហរណ៍មួយវរសេនាតូចខ្ញុំពេទ្យ អីចឹងខ្ញុំយាមការពារតែពេទ្យខ្ញុំហ្នឹងទៅ វរសេនាតូច០៦គេយាមការពាររបស់គេទៅ ។

ដានី: អត់ទេ ខ្ញុំចង់មានន័យថានៅកន្លែងដូចថាមន្ទីរកងពលមួយ ដូច៨០១មានគុក? មន្ទីរ សន្តិសុខ?

សារឿន: អត់មានទេ មន្ទីរ៨០១នៅក្នុងវ៉ឺនសៃ អត់មានទេ តែគេមកធ្វើគុកនៅបាងលុង ។

ដានី: ហ្នឹងគុករបស់អីគេ?

សារឿន: ហ្នឹងគុករបស់កងពល ។

ដានី: គុកកងពល?

សារឿន: គុកកងពល តែមិនដឹងមានមនុស្សប៉ុន្មានៗ យើងក្តាប់មិនបានទេ តែដឹងតែកងពលអ្នកណា មានបញ្ហាគេចាប់បញ្ជូនទៅហ្នឹង ។

ដានី: លោកពូដឹងថាភាគច្រើនអ្នកដែលគេចាប់ទៅកន្លែងគុកហ្នឹង ច្រើនតែមានបញ្ហាអី ខុសអី ហើយអ្នកហ្នឹងចាប់ទៅចាប់ទៅយ៉ាងម៉េច គ្រាន់តែកសាងខ្លួនហើយត្រឡប់មកវិញ? ឬទៅ គេត្រូវបញ្ជូនទៅលើទៀត ឬអ្នកខ្លះត្រូវកំទេចអីយ៉ាងម៉េច? លោកពូមានដឹងទេ?

សារឿន: ខ្ញុំបញ្ហាហ្នឹងខ្ញុំក្តាប់អត់បានដែរ ព្រោះពេលនោះឃើញអ្នកចាប់ទៅភាគច្រើនត្រឹមវរៈ ចាប់ ច្រើនបញ្ជូនទៅលើទៀត បញ្ជូនទៅភ្នំពេញថាទៅរៀន បើសិនជាអ្នកមានកំហុសតូចតាច លួចស៊ីចុកលិចកើត គេទុកមកអង្គភាព គេទុកមុំ អ្នកខុសវិន័យលិចកើត ខុសសីលធម៌អី លិចកើត គេទុកមុំតែអត់ដែលធ្វើអីទេ អ្នកហ្នឹងឃើញ៧៩មករស់នៅរត់តាមព្រៃ ។

ដានី: ដូចឈ្មោះ ឡាយ សារឹម, ឈ្មោះ ឡូច, ឈ្មោះ ហាន អីដែលលោកពូថាគេយកទៅ គេចាប់បញ្ជូនមកកន្លែងគុករបស់កងពលសិន ឬអត់ទេ?

សារឿនៈ អត់ទេ ចាប់បញ្ជូនហ្នឹងអ្នកភ្នំពេញហៅតែម្តង ហៅទៅរៀននៅភ្នំពេញ គុកយើងនៅតាមបាផលុងគុកតូចតាចចាប់តែអ្នកខុសវិន័យ មេធំៗត្រឹមវរៈបញ្ជូន ប្រធានវរៈ បញ្ជូនទៅហួសៗ ភ្នំពេញគេមានចម្លើយកៅហៅទៅបណ្តោយ ។

ដានី: កាលហ្នឹងពូដឹងដែរមានចម្លើយពីភ្នំពេញមក?

សារឿនៈ មាន ដឹង ព្រោះខ្ញុំនៅមន្ទីរធ្វើការងារត្រឹមអនុសេនាតូច តែគេប្រាប់ថាគេហៅបងនោះទៅរៀន គេមកប្រាប់អីចឹង ។

ដានី: តែក្នុងចិត្តយើងពេលដែលលឺថាគេហៅមករៀនអីចឹង ប្រាកដគាត់ត្រូវគេចាប់ ឬក៏យ៉ាងម៉េច?

សារឿនៈ អត់ដឹងទេ ។

ដានី: គេហៅយើងត្រង់ធម្មតា?

សារឿនៈ អត់ដឹងទេ ដល់ពេលក្រោយមកបាត់ បានលឺសូរព័ត៌មានក្រោយមកថាគេចាប់ ។

ដានី: ពូឆាង ម៉ិញជាប្រធាននៅកន្លែង?

សារឿនៈ មានពីរតែខ្ញុំអត់ដឹងថា តាឆាង ហ្នឹងប្រធានឬអ្នកណាទេ ។

ដានី: មានអ្នកណា?

សារឿនៈ មានតាអួយ ហ្នឹងមួយ, មានតាឆាង ពីរ ។

ដានី: មានតាអួយ មួយ, តាឆាង មួយ?

សារឿនៈ បាទ! តាអួយ និងតាឆាង ព្រោះឥឡូវ (៤៨:៣៩) ចាំតែប៉ុណ្ណឹងទេ តែមិនដឹងថាគេធ្វើកិច្ចការងារអីក៏ខ្ញុំមិនដឹងដែរ ។ តាអួយ ស្លាប់បាត់ហើយ ។

ដានី: លោកពូកាលហ្នឹងខាងលើ ខាងសេនាធិការ គេធ្លាប់ចុះទៅខាងរតនគិរីហ្នឹងដែលអត់?

សារឿនៈ អត់ដែលឃើញចុះទេ ។

ដានី: អត់ដែលចុះ?

សារឿនៈ មានតែហៅកងពល តា០៥ ឡើងមក អត់ដែលចុះទេ ។

ដានី: តាមេត, តាម៉ុត អីគាត់ធ្លាប់ទៅទេ?

សារឿនៈ អត់ទេ ។

ដានី: សុន សេន អី?

សារឿនៈ អត់ទេ មាន វ៉ន វេត ទៅម្តង ចុះយន្តហោះនឹងព្រលានយើងធ្វើនសៃហ្នឹង ចុះមួយភ្លែតឡើងមកវិញ ។

ដានី: គេឡើងមក?

សារឿនៈ ទៅភ្នំពេញ ។

ដានីៈ តា០៥ អីទៅជាមួយគាត់អត់?

សារឿនៈ អត់ទេ វ៉ន វ៉េត ចុះមកឡើងទៅភ្នំពេញទៅ លឺសូរចុះពីយន្តហោះគេចាប់គាត់នៅភ្នំពេញដែរ ចាប់ វ៉ន វ៉េត ។

ដានីៈ ឆ្នាំណាហ្នឹង?

សារឿនៈ ឆ្នាំ៧៨ ។

ដានីៈ ចុងឆ្នាំ ឬដើមឆ្នាំ?

សារឿនៈ កាលហ្នឹងខែវស្សា វៀតណាមកិកី មានបញ្ហាតិចតួចៗរហូត ។

ដានីៈ លោកពូទាក់ទងនឹងកងពល ហើយនឹងភូមិភាគឥសាន កាលហ្នឹងដល់ពេលមិនមានខាងភូមិភាគគេហៅទៅភ្នំពេញច្រើន?

សារឿនៈ ដូចអត់យល់ទេ ការងារភូមិភាគ ។

ដានីៈ ប៉ុន្តែកាលហ្នឹងដូចថាខាងគណៈដឹកនាំ ខាង៨០១ ខាងវរសេនាធំមួយចំនួនត្រូវដកទៅកាន់ខាងភូមិភាគ កាន់តំបន់ច្រើនអត់?

សារឿនៈ អត់ទេ កាលហ្នឹងអត់មានទេក្នុងកងពល៨០១ហ្នឹង អត់មានដកទេ បើដកៗពីនីរតីមកមានកាន់តំបន់ស្ទឹងត្រែង, លំផាត់ មានដកពីនីរតីមក ដកហ្នឹងដកឆ្នាំ៧៧ ដកដិះយន្តហោះមកទៀត ដាក់យន្តមកចុះនៅវ៉ើនសៃហ្នឹង បានចែករំលែកតាមតំបន់ ។

ដានីៈ លោកពូស្គាល់គ្នាទេកាលហ្នឹង?

សារឿនៈ កាលហ្នឹងខ្ញុំអត់ស្គាល់ទេ ខ្ញុំគ្រាន់តែជាអ្នកធ្វើពេទ្យហើយ គេឲ្យខ្ញុំយាមព្រលាន ខ្ញុំដឹងកិច្ចការងារព្រលានយន្តហោះហ្នឹង ខ្ញុំការពារសន្តិសុខព្រលានហ្នឹង ។

ដានីៈ ក្រែងព្រលានយន្តហោះមួយៗ ខាងកង៥០២គេមកយាម?

សារឿនៈ មានគេយាម តែលើបញ្ហាយន្តហោះមួយទេ សន្តិសុខគឺនៅលើយើង គេបញ្ជាតែយន្តហោះចុះឡើងសហការជាមួយយើងអ្នកការពារសន្តិសុខហ្នឹង ។ ព្រលឹមឡើងខ្ញុំឲ្យក្មេងក្នុងបរអាឡូកាន់ថ្នល់យន្តហោះ ពេលគេចុះយន្តហោះ ខ្លាចមានមីន ដល់ចុះដឹងតែអត់មានសុវត្ថិភាពហើយ ខ្ញុំទៅយាមកាមចុងព្រលាន យន្តហោះគេចុះមក លឺសូរគេនិយាយអីចឹងមានការងឹងឆ្ងល់ ។

ដានីៈ លោកពូនៅតំបន់វ៉ើនសៃហ្នឹងខាងនីរតីគេទៅឈ្មោះអីទៅ?

សារឿនៈ នីរតីគេទៅគ្រប់គ្រងខ្ញុំមិនចាំត្រកូលទេ ទី១ តាយឹម ។

ដានីៈ យឹម គាត់ទៅណា?

សារឿនៈ មិនដឹងគាត់នៅតំបន់ណា លំដាត់អីតាយីម ។

បូលីៈ ព្រំ យីម យើងនេះ?

សារឿនៈ ព្រំ យីម ហ្នឹងហើយ

បូលីៈ ហ្នឹងឯង ។

សារឿនៈ ហើយទី១ទៀតឈ្មោះ រឿន ក្រៅពីហ្នឹងខូចអស់ហើយ ខ្ញុំភ្លេចឈ្មោះ ។

ដានីៈ ហ្នឹងគាត់ទៅខាងលំដាត់?

សារឿនៈ បាទ ។

ដានីៈ គាត់ជាគណៈតំបន់?

សារឿនៈ គាត់បែបនៅគណៈតំបន់ហើយតាមមើល ។

បូលីៈ ចូលគណៈហើយ តែទៅចុងដៃហើយ ។

ដានីៈ រឿន មួយទៀត?

សារឿនៈ រឿន មួយទៀតនៅកងពល ។

ដានីៈ រឿន ប្រពន្ធគាត់យាយរួន?

សារឿនៈ ហ្នឹងហើយ សុទ្ធពួកទៅពីនេះ ។

ដានីៈ តារឿន ហ្នឹងគាត់ទៅនៅ?

សារឿនៈ ទៅស្ទឹងត្រែង ។

ដានីៈ តារឿន កងពល៨ ហើយតាយីម ។

បូលីៈ តាយីម ដូចនៅក្រចេះទេ ។

ដានីៈ លោកពូមានចាំពីណាទៀត?

សារឿនៈ អត់ដឹងពីណាដែរ ខ្ញុំចាំតែពីរហ្នឹង ។

ដានីៈ ខាងតា០៥ គាត់មកគ្រប់គ្រងនៅភូមិភាគដែលអត់?

សារឿនៈ អត់ទេ គាត់នៅតែកងពល គាត់នៅរហូតដល់៧៩ រៀតណាមចូលស្រុក គាត់ចូលព្រៃ ។

ដានីៈ យ៉ាងម៉េចទៅលោកពូពេលចូល៧៩?

សារឿនៈ ៧៩ ។

ដានីៈ សភាពការណ៍យ៉ាងម៉េច? ហើយលោកពូទៅណាមកណាទៅដល់ពេលឆ្នាំ៧៩?

សារឿនៈ ឆ្នាំ៧៩ចូលព្រៃនៅរតនគិរីហ្នឹង នៅតាមជុំវិញភូមិ វើនសៃ, សៀមបាង នៅជីកដំឡូង ហូបមួយឆ្នាំ៧៩ពេញ ជីកដំឡូង ជីកក្ដួច ហូចអីចឹងទៅ ។

ដានីៈ លោកពូនៅកងពលដដែល ឬយ៉ាងម៉េច បែកខ្ញែកគ្នា?

សារឿនៈ ដល់នោះ ដល់ពេលបែកខ្មែរគ្នាខ្ញុំលែងដឹកនាំអង្គភាពពេទ្យហើយ ខ្ញុំមកនៅធ្វើកងពិសេសរបស់តាកែវហើយ គេរំលាយពួកពេទ្យខ្ញុំលែងឲ្យនៅជុំគ្នាទៅ វាអត់មានអ្នកណាគ្រប់គ្រងអត់មានកន្លែងព្យាបាលពិតប្រាកដ គេរំលាយឲ្យយើងទៅនៅកងពិសេសគ្នា៥នាក់ ។

ជានីៈ ខ្ញុំភ្លេចមួយទៀត តាជុំ ជាតិ?

សារឿនៈ តាជុំ នៅនេះ តាជុំ ខ្ញុំក្លាប់អត់បានទេ ព្រោះតាជុំ មកនៅភូមិភាគកណ្ដាល គាត់គេដកមកភូមិភាគកណ្ដាល ។

ជានីៈ ដកឆ្នាំណា?

សារឿនៈ មិនដឹងឆ្នាំប៉ុន្មាន ព្រោះតាជុំ ពីដើមឈ្មោះតាហ៊ិន ហុងហៅ ។

ជានីៈ ហ៊ិន ហុងហៅ?

សារឿនៈ បាទ! គាត់កាន់វរៈ ។

ជានីៈ កាន់វរៈនៅណា?

សារឿនៈ វរៈ២៣ វរៈតំបន់នៅតំបន់១៥យើង នៅខាងជើងភ្នំពេញ ។

ជានីៈ គាត់អត់បានទៅរតនគិរីជាមួយទេ?

សារឿនៈ គាត់ទៅតែមិនគេដកគាត់ថ្ងៃណា តែគាត់ទៅ គាត់ដឹងតែនៅ៨១ តែមិនដឹងថាគាត់ធ្វើអីតាហ៊ិន ។

បូលីៈ តាហ៊ិន ហុងហៅ អីចឹងតែម្ដង ។

សារឿនៈ បាទ! តាហ៊ិន ហុងហៅ ពីមុនឈ្មោះអីចឹង ដល់ពេលក្រោយមកដាក់ឈ្មោះជុំ ថាសម្ដេចឲ្យឈ្មោះ ជុំ ជាតិ ម៉េចទៀត ។

ជានីៈ គាត់កាលនៅតំបន់១៥ គាត់ប្រធានវរសេនាតូច?

សារឿនៈ វរសេនាតូចតំបន់ ។

ជានីៈ វរសេនាតូចតំបន់១៥?

សារឿនៈ បាទ!

ជានីៈ ដល់ពេលក្រោយ៧៥ ទៅរតនគិរី នៅវរសេនាធំ៨១ តែមិនដឹងជាតួនាទីគាត់ជាអី?

សារឿនៈ បាទ! មិនដឹងធ្វើអី ។

ជានីៈ ក្រោយមកឆ្នាំណាគេដកគាត់មកភូមិភាគកណ្ដាលវិញ?

សារឿនៈ អត់ដឹង ខ្ញុំដូចជាភ្លេចអត់ចាំ ។

ជានីៈ អីចឹងលោកពូពេល៧៩មកយ៉ាងម៉េចទៀត?

សារឿនៈ ពេល៧៩មកចូលព្រៃមួយឆ្នាំ នៅតាមភូមិដាច់ស្រយាលដញ្ជូនស្រូវ អង្ករអីលាក់ទុកហូប ហ្នឹងបានកន្លះឆ្នាំ បន្ទាប់ពីកន្លះឆ្នាំហ្នឹងមកហូបដំឡូង ហូបក្តួច ដល់ខែ៩ ឆ្នាំ៨០ហ្នឹងបានឆ្លង ទន្លេមេគង្គហែលមកយើងក្នុងវែក ។

ដានីៈ ខែ៩ ឆ្នាំ៨០?

សារឿនៈ បាទ! ខែ៩ ឆ្នាំ៨០ ។

បូលីៈ បានយូរផង ។

សារឿនៈ បាទ! បានយូរ ។

បូលីៈ មិនមែន៧៩ទេ?

សារឿនៈ មិនមែន៧៩ទេ ចូល៨០ហើយ ។

បូលីៈ វៀតណាមវាយខែមករា ឆ្នាំ៧៩?

សារឿនៈ នៅៗ ក្នុង៧៩ ខ្ញុំឡើងក្នុងដល់ឆ្នាំ៨០ ។

ដានីៈ អ៊ីចឹងខែ៩ ឆ្នាំ៧៩?

សារឿនៈ បាទ! ខែ៩ ៧៩ ។

ដានីៈ លោកពូមានប្រសាសន៍កន្លែងហ្នឹង ពេលហ្នឹងយើងដូចថាពេលហ្នឹង យើងចេញពីត្រឹមណា មកត្រឹមណា ហើយឆ្លងពីត្រឹមណាមក ពីឆ្នាំ៧៩?

សារឿនៈ រឿងប្រវត្តិឆ្លងទន្លេ?

ដានីៈ បាទ! យ៉ាងម៉េចឆ្លងកន្លែងណា? ហើយឆ្លងប៉ុន្មាននាក់ទៅ?

សារឿនៈ ខ្ញុំកាលនោះឆ្នាំ៧៩ ខែ៨-៩ហ្នឹងខ្ញុំលួចទូកឆ្លងយើងនៅកោះខាំ ខាងក្រោមព្រះវិកិល ខាងក្រោមអូររុននេះ លួចទូក ខ្ញុំអត់ដែលលួចទូកប្រជាជនទេ គឺថ្ងៃនោះខ្ញុំដើរចូលទៅលួចទូកយួន មានបន្ទាយ បន្ទាយគេនៅអ៊ីចឹង ផ្លូវមុខបានទៅមាត់ទន្លេ។ ខ្ញុំដើរទៅដឹងថាបន្ទាយយួន យួនចាក់សុទ្ធតែច្រវ៉ាក់ អ៊ីចឹងខ្ញុំមួលកាច់មកបានទូក២ យកមកលាក់ ហើយខ្ញុំឡើងមកជួបបងកែវ យើងហ្នឹង ។ ជួបបងកែវ គាត់មើលខ្ញុំបាន១អាទិត្យ បានខ្ញុំឆ្លងមក ។

ដានីៈ កាលហ្នឹងបងកែវ គាត់មេ?

សារឿនៈ ប្រធានវរសេនាធំ ។

ដានីៈ ដល់ពេល៧៩មកប្រធានវរសេនាធំ?

សារឿនៈ បាទ! គេដាក់ចំរុះគ្នាជាមួយ៨០២ ជាមួយ០៣ហ្នឹងធ្វើមួយវរសេនាធំ ។

ដានីៈ វរសេនាធំលេខប៉ុន្មានទៅ?

សារឿនៈ ៨៤ ។

ដានី៖ នៅក្នុងចំណុះកងពល?

សារឿន៖ ៨០១ហ្នឹងដដែល គេរៀបក្នុងព្រៃហ្នឹង។

ដានី៖ អីចឹងគាត់ឡើងជាវរសេនាធំហ្នឹងក្រោយ៧៩ ពេលយួនចូលហើយ?

សារឿន៖ ក្រោយ៧៩ទេ។

ដានី៖ លោកពូជាស្អីវិញទៅកាលហ្នឹង?

សារឿន៖ កាលនោះខ្ញុំគេឲ្យទៅធ្វើមេក្រុមកងពិសេសរបស់តាកែវហ្នឹង។

ដានី៖ មេក្រុមកងពិសេសរបស់វរៈតែម្តង?

សារឿន៖ បាទ! របស់វរសេនាធំហ្នឹង។

ដានី៖ បាទ! បន្តទៀតលោកពូ។

សារឿន៖ ដល់ពេលហែលទឹកមកចូលកោះ គ្នា៣០នាក់មានស្រីទាំងប្រពន្ធខ្ញុំហ្នឹង ទាំងអស់៨នាក់ស្រី ដល់លើកោះខ្ញុំឲ្យបងប្អូនសំរាកហ្នឹង កុំឲ្យផ្ទេកឆ្ងាតនៅឲ្យស្ងៀមទៅ ឲ្យកាត់ឫស្សីធ្វើក្បូនឆ្លង មួយទុកទៀត ទន្លេមេគង្គធំប្រហែល១០០ម៉ែត្រ។ ដល់ពេលកាត់ហើយម៉ោង៣រសៀល ចាប់ផ្តើមឆ្លង ឆ្លងហែលទឹកដល់ត្រើយនាំគ្នាស្រាយឥវ៉ាន់ឡើងចេញព្រលែងក្បូនទៅ ក៏ដើរមកជួបកំលាំងគេចុះពីភ្នំដងរែកទៅយកនៅភូមិក្រាយឥន្ទ។

បូលី៖ ភូមិអីគេ?

សារឿន៖ ភូមិក្រាយឥន្ទយើងនៅក្នុងស្រុកឆែប។

ដានី៖ លោកពូដែលឆ្លងកាត់ទន្លេ កន្លែងព្រះរំកិល?

សារឿន៖ ក្រោមព្រះរំកិល។

ដានី៖ ក្រោមព្រះរំកិលក្នុងស្រុកណា?

សារឿន៖ នៅក្នុងស្រុកថាណាបរិវ៉ាត់។

បូលី៖ កៀកឡាវហើយ?

សារឿន៖ បាទ! ខាងក្រោមឡាវ ក្រោមជួរបាក់ភេន។

បូលី៖ ជួរបាក់ភេនបន្តិច?

សារឿន៖ ជួរបាក់ភេនបន្តិច ចុះមកប្រហែលឆ្ងាយដែរ លីសួរទឹកធ្លាក់។

បូលី៖ អីចឹងបើសិនជាលីសួរកៀកមែនទែន?

សារឿន៖ កៀក ព្រោះកន្លែងហ្នឹងមានកោះមួយគេហៅសុខាំ ជិះទូកឆ្លងមកទើលើកោះស្មានតែត្រើយ បុកកោះ ដល់ព្រលឹមឡើងខ្ញុំដើរមកមើលកោះនៅទឹកម្ខាងទៀត បានឲ្យគេកាប់ឫស្សីឆ្លងមក ទៀត។

ដានី៖ នៅលើកោះហ្នឹងមានឫស្សីទៀត?

សារឿន៖ នៅលើកោះមានឫស្សី ។

បូលី៖ ចុះទូកយើងជិះមកព្រលែងចោល?

សារឿន៖ ទូកអត់ព្រលែងទេ ទូកជិះមកឲ្យកំលាំងទៅយកបកក្រោយមកវិញ ដើម្បីចម្លងអ្នកក្រោយទៀត យកមកគេលាក់ទុកទៅ គេចម្លងបាន២ជើងទៀតបានបែកការណ៍ដល់យួន បែកការណ៍ដល់យួនលាក់ទូកចោលក្នុងទឹក ។ ធម្មតាទូកយើងពន្លិចជិត ជន្លិចក្នុងទឹកអត់អ្នកណាឃើញទេ ។

បូលី៖ អស់នៅ? ចម្លងមកអស់នៅ?

សារឿន៖ ចម្លងអត់អស់ទេ ចម្លងមកបានតែកំលាំង៨០នាក់ហ្នឹង ២-៣ជើងបានតែ៨០នាក់ ។

ដានី៖ កំលាំងទាំងអស់ប៉ុន្មានទៅ?

សារឿន៖ កំលាំងទាំងអស់ជាប់៥០០០នាក់ជាង កំលាំងកងពល៨០១មិនមែនតិចទេ តាមវរសេនាធំគេ អានេះចម្លងតែពួកមន្ទីរ ជុំវិញមន្ទីរ ។

បូលី៖ អ្នកផ្សេងធ្វើម៉េចទៅអីចឹង?

សារឿន៖ អ្នកផ្សេងក្រោយមកខ្ញុំមកដល់នេះ មកដល់ភ្នំដងរែក ខ្ញុំមានបាយហូប ខ្ញុំបកទៅវិញធ្វើផ្លូវឆ្លង ខ្ញុំទៅឆ្លងកាត់ឡាវ ស៊ិននៅមេមន់ ចម្លងទ័ពបានប៉ុន្មាន២០០០នាក់ជាង ហែលទឹកឆ្លងទន្លេមេគង្គ ឆ្លងមកយកមក ។

ដានី៖ លោកពូមានប្រសាសន៍ហ្នឹងលោកពូមកដល់ដងរែក មកដល់មុំ៣ហ្នឹងមុនគេ?

សារឿន៖ បាទ! ខ្ញុំមកដល់មិនមែនមុនទេ តែខ្ញុំមកក្នុងអង្គភាពខ្ញុំមុនគេ តែមានគេអ្នកមកមុនខ្ញុំ គេមកខែប្រាំងទៀត ។

ដានី៖ ពីណាគេមកមុនគេ?

សារឿន៖ មានក្រុមពួកតាម៉ៅគេមកមុនខ្ញុំទៀត ។

ដានី៖ ក្រុមតាម៉ៅ វរៈ៨១ហ្នឹង?

សារឿន៖ បាទ! វរៈ៨១គាត់មកមុនខែប្រាំង គេមកខែ៤ ខ្ញុំមកខែ៨ហើយ ។

ដានី៖ មុនតាម៉ៅ ហ្នឹងមានអត់?

សារឿន៖ មុនតាម៉ៅ ហ្នឹងមានកងមន្ទីររបស់តាម៉ុក គេនៅប្រចាំ ទាក់ទងព្រំដែនមុំ៣ ។

ដានី៖ កងមន្ទីររបស់តាម៉ុក គាត់នៅមុនគេ?

សារឿន៖ គាត់នៅមុនគេ ។

ដានី៖ គាត់នៅតាំងពីអន្លង់វែងមក?

សារឿនៈ គាត់នៅខ្ទង់៧៩ គាត់រត់មកដល់ភ្នំដងរែក គាត់មករៀបរយទំនាក់ទំនងថៃ ។

ដានីៈ គាត់នៅដំបូងគេ គាត់នៅកន្លែងមុំ៣ ឬគាត់មាននៅកន្លែងផ្សេងទៀត?

សារឿនៈ មុនដំបូងគាត់នៅគេហៅស្ពី ១០០២ ។ ដល់ពេល១០០២ គាត់ទៅនៅកើតទន្លេណ្តៅគេហៅ១០០១ ។

បូលីៈ មួយណាកើតមុនពីរហ្នឹង?

សារឿនៈ ១០០២នេះកើតមុន ១០០១ កើតក្រោយ ។

ដានីៈ ខ្ញុំលឺអ៊ំ ពូ មីងមួយចំនួនគាត់ថា ដំបូងមកនៅកន្លែង៨០៨ ។

សារឿនៈ ៨០៨ នៅខាងលិចអន្លង់វែង ។ ៨០៨ភ្នំមួយលិចអន្លង់វែង ។

ដានីៈ មួយណាមុន មួយណាក្រោយ?

សារឿនៈ វាមានមួយបន្ទាត់ព្រំដែនវាមានច្រើន អីចឹង៨០៨, ១០០៣, ១០០២ ។ ១០០៣នៅច្រកអូរ៥០ អន្លង់វែងហ្នឹងតែម្តង នេះ១០០២ ហើយនោះក្រោយគេ អីចឹងមួយខេត្តហ្នឹងមិនដឹងអាមួយណាមុន អាណាក្រោយ ។ តែខ្ញុំដឹងថា៨០៨ក៏មុន ១០០៣ក៏មុនតែគេនៅពេលជុំគ្នា ដល់ពេលជុំគ្នាគេបំបែកមកតាមច្រក ។ គេរៀបគ្នាមួយបណ្តោយតែមិនដឹងមួយណាកើតមុន ។

ដានីៈ តែកើតក្នុងឆ្នាំណា?

សារឿនៈ ក្នុងឆ្នាំ៧៩តែមួយ ។

ដានីៈ ៧៩តែមួយទេ?

សារឿនៈ តែជិតដាច់ចូល៨០ហើយ ។ បើនិយាយឲ្យពេញលេញឆ្នាំ៨០ ។

ដានីៈ អីចឹងទាំងអស់ហ្នឹងក្រុមណាមកមុនគេ?

សារឿនៈ វារត់មានពីរសណ្ឋាន រត់ទី១ឆ្នាំ៧៩ រត់ភ្លាមអ្នកមកដល់ភ្លាម ។

ដានីៈ អ្នកណាគេ?

សារឿនៈ ខ្ញុំអត់ដឹងទេ ។

ដានីៈ បើមេៗ អ៊ំៗ អ៊ំណាមកដល់មុន?

សារឿនៈ អត់ទេ អត់ដឹងអ៊ំណាមកមុនគេទេ ព្រោះអ៊ំៗគាត់រត់ធ្លាក់កោះកុងទាំងអស់ ស្ទឹងមេទឹកអត់មានរត់ច្រកនេះទេ គាត់ទៅដល់នោះបានរុញកំលាំងឲ្យមកទំនាក់ទំនងតាមច្រកនេះដើម្បីអូសទាញកំលាំងពីភូមិភាគឥសានមក ។

ដានីៈ ខ្ញុំយល់ហើយ អ៊ំៗដំបូងរត់ទៅខាងស្ទឹងមេទឹក ទៅខាងកោះកុង ពោធិ៍សាត់នោះ?

សារឿនៈ កោះកុង ពោធិ៍សាត់ ត្រាក សំឡូត ។

ដានី:	ដល់ពេលហើយចេញពីហ្នឹងមកវិញ?

សារឿន:	ហើយទៅដល់ហ្នឹងគាត់រាយអ្នកដឹកនាំគាត់មកនេះវិញ ដើម្បីសួចអ្នកដឹកនាំពីឥសានមកទំនាក់ទំនងគ្នា យកទូរលេខ ឲ្យអ្នកនៅលើភ្នំមួយចំនួនយកទូរលេខឲ្យអ្នកនោះដើម្បីទាក់ទងគ្នាឲ្យចងក្រងកំលាំងកុំឲ្យបែកទៅណា ។

ដានី:	ចុះតាម៉ុក គាត់មកពីអន្លង់វែង?

សារឿន:	តាម៉ុក ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំមកលើភ្នំឆ្នាំ៧៩-៨០នេះ ចុង៧៩វាដល់៨០ហើយ មកឃើញតាម៉ុក នៅលើភ្នំហើយ ។

ដានី:	នៅលើភ្នំណា?

សារឿន:	នៅ១០០១ហ្នឹង ។

ដានី:	ចុះតាសុន សេន?

សារឿន:	តាសុន សេន គាត់ទើបតែមកពីលិចក្រោយទេ គាត់ទើបតែមកពីប៉ៃលិនក្រោយ ។

ដានី:	តាសុន សេន គាត់ទៅណាដែរ?

សារឿន:	តាសុន សេន អត់ដឹងទៅណា តែគ្រាន់តែឃើញក្រោយមក គាត់មកដឹកនាំនៅ១០០១ហ្នឹង ដកតាម៉ុក មកនៅ១០០៣ ។

ដានី:	អីចឹងដំបូងគេតាម៉ុក គាត់នៅហ្នឹងទេ?

សារឿន:	បាទ! តាម៉ុក ទៅនៅចាត់ចែងហ្នឹង ដល់ពេលកំលាំងមកបានច្រើនតិច ភូមិភាគកណ្តាល ភូមិភាគឥសាន មកជុំគ្នាបាន៣០០-៥០០នាក់ បានដកតាសុន សេន ឲ្យមកគ្រប់គ្រងនៅមុំ៣ហ្នឹង ។

ដានី:	ដំបូងគេឃើញក្រុមតាម៉ុក គាត់នៅហ្នឹង បានក្រុមរបស់លោកពូដែលមានវរៈធំ៨១ តាម៉ៅហ្នឹងគាត់ទៅមុន?

សារឿន:	តាម៉ៅ គាត់ឡើងមុន គាត់មកខែ៤ ហើយគាត់បានមកដល់ហើយ គាត់បានឥវ៉ាន់ហើយ គាត់យកទូរលេខទៅឲ្យពួកខ្ញុំ ស្រណុកទំនាក់ទំនងមកលើដឹងថាជុំគ្នា កំលាំងអត់អីហើយបានសារ៉េឲ្យឆ្នង ។

ដានី:	លោកពូ១០០១ បើយើងនិយាយទៅទីតាំងវាពីត្រឹមណា ដល់ត្រឹមណា?

សារឿន:	១០០១គេរាប់ពីអូរធំនេះលិច ទន្ទឹមនឹងបើយើងគិតទៅខាងក្រោម ពីអូរធំនេះ និយាយរួមវាកៀកនឹងពោយព្រិច ។

ដានី:	ស្រុកអីគេឥឡូវ?

សារឿន:	ពោធិ៍ព្រិច ស្រុកជាំក្សាន្ត គេគិតពីត្រឹមហ្នឹងទៅកើត ។

ដានី៖ ពីពោយព្រិច ពីជាំក្សាន្ត បានន័យថាពីខាងអាងសេះវិញ ។

សារឿន៖ បាទ! ពីខាងកើតអាងសេះទៅ ។

ដានី៖ ហួសមកខាងអាងសេះ?

សារឿន៖ ហួសខាងកើតអាងសេះដី៥-៦គីឡូ ។

ដានី៖ ចុះបើយើងគិតពីប្រាសាទព្រះវិហារកាលហ្នឹងនៅក្នុង?

សារឿន៖ អត់ទេ អត់មានដល់ព្រះវិហារ ព្រោះអាងសេះនៅខាងកើតព្រះវិហារទៀត ។

ដានី៖ អ៊ីចឹងចាប់ពីអាងសេះ ទៅដល់មុំ៣?

សារឿន៖ អត់ទេ ខាងកើតអាងសេះបន្តិចទៀត ។

ដានី៖ ខាងកន្លែងណាទៅ?

សារឿន៖ ខាងកើតអាងសេះដីប្រហែល១០គីឡូ ។

ដានី៖ ខាងកើតបានន័យថា?

សារឿន៖ ពោយព្រិច គេហៅដាក់ងារ នៅស្រុកជាំក្សាន្តត្រឹមពោយព្រិចទៅកើត ។

ដានី៖ ទៅខាងទន្លេល្ពៅ?

សារឿន៖ បាទ! ទៅខាងទន្លេល្ពៅ ។

ដានី៖ ទៅទល់នឹងទន្លេល្ពៅតែម្តង?

សារឿន៖ ទៅទល់នឹងព្រំដែនឡាវ ព្រោះកាលហ្នឹងថៃពីក្រោយអត់មានបញ្ហាទេ ឡាវក៏អត់មានបញ្ហាដែរ ។

ដានី៖ ហើយមានប៉ុន្មានកងពលដែលច្រក១០០១?

សារឿន៖ ច្រក១០០១មានកងពល៨០១ហ្នឹងមួយ, កងពលភូមិភាគកណ្តាលរបស់តាពក ទៅហ្នឹងទាំងអស់ ។

ដានី៖ កណ្តាលរបស់តាពក ។ មានតែ២កងពលហ្នឹងដំបូង?

សារឿន៖ បាទ! មានតែ២ហ្នឹងដំបូង ក្រោយមកបាន៩២០ឡើងមកមួយទៀត ។

ដានី៖ ឆ្នាំណាដែល៩២០ឡើងមកមួយទៀត?

សារឿន៖ ខ្ទង់ឆ្នាំ៨១ ចុង៨០ដើម៨១ ។

ដានី៖ មកក្រោយគេទេ៩២០ហ្នឹង?

សារឿន៖ ក្រោយ ។

ដានី៖ យ៉ាងម៉េចបាន៩២០មកក្រោយគេ?

សារឿនៈ មិនដឹងជាយ៉ាងម៉េច ព្រោះគេទំនាក់ទំនងតាមរយៈតា០៥ ហើយខ្ញុំមិនយល់ថាគាត់មានទំនាក់ទំនងយ៉ាងម៉េចបានជាយឺត ។

បូលីៈ អាចគាត់នៅឆ្ងាយ ព្រោះមណ្ឌលគិរីវាឆ្ងាយជាងគេ ។

សារឿនៈ បាទ! មណ្ឌលគិរី ។

ដានីៈ អីចឹងអ្នកដែលមកដល់មុន ដែលកងពលមកដល់មុនគេ?

សារឿនៈ កងពលមកដល់មុនគេ៨០១ហ្នឹងហើយ ។

ដានីៈ ៨០១មុន?

សារឿនៈ បាទ! តាម៉ៅ ។

ដានីៈ ឆ្នាំចុងឆ្នាំ៧៩?

សារឿនៈ ៨០ហើយ ចុង៧៩ ដើម៨០ តែក្នុងរដូវប្រាំង ព្រោះ៧៩យើងបែករដូវប្រាំងហើយ ។

ដានីៈ កងពលខាងភូមិភាគកណ្ដាល?

សារឿនៈ ភូមិភាគកណ្ដាលមកមួយសារៗគ្នាហ្នឹង មុនក្រោយគ្នាតិចតួចហ្នឹង ។

ដានីៈ បន្ទាប់ៗហ្នឹង?

សារឿនៈ បន្ទាប់ៗគ្នា ។

ដានីៈ មកចុងក្រោយ៩២០?

សារឿនៈ បាទ! ៩២០ ។

ដានីៈ ៣កងពលហ្នឹងនៅជាប់រហូត ឬមានថែមថយកងពលនៅប្រក១០០១ហ្នឹងទៀត?

សារឿនៈ អត់មានទេ មានតែកងពលហ្នឹងមួយទេ ។

ដានីៈ មានតែ៣ហ្នឹងទេ?

សារឿនៈ ខាងនោះវាមានចំរុះសុទ្ធតែពួកផ្សេង ។

ដានីៈ ផ្សេងណាយ៉ាងម៉េច?

សារឿនៈ មានពួកឡាវក្រហមតស៊ូប្រឆាំង ឡាវសព្វថ្ងៃនេះមួយក្រុម តែមិនដឹងគ្នាប៉ុន្មានទេ គ្រាន់តែមានទំនាក់ទំនងហ្នឹងដែរ ។ ហើយមានពួកដេការប៉ូរ៉ូវៀតណាមនោះនៅហ្នឹងមួយក្រុមដែរ ។

បូលីៈ ហ្វុយរ៉ូ?

សារឿនៈ បាទ! ហ្វុយរ៉ូ ។

ដានីៈ ក្រុមហ្នឹងដូចក្រុមឡាវក្រហម, ដេការហ្វុយរ៉ូ ត្រូវជាមួយខ្មែរក្រហមយើង ឬប្រឆាំង?

សារឿនៈ ត្រូវជាមួយខ្មែរក្រហម អំណោយ ជំនួយយកពីខ្មែរក្រហមទាំងអស់ អាវុធគ្រាប់រំសេវយកពីហ្នឹងទាំងអស់ ។

ដានី៖	ខ្មែរក្រហមជួយទៅខាងហ្នឹងវិញ?

សារឿន៖	ចែករំលែក ។

ដានី៖	ដើម្បីវៃប្រឆាំងជាមួយខាងរដ្ឋាភិបាលឡាវ ។

សារឿន៖	បាទ ។

ដានី៖	ដេការហុយរ៉ូ ក៏វៃជាមួយឡាវដែរ?

សារឿន៖	យួន ។

ដានី៖	អ៊ំ! ពួកហ្វូរ៉ូមកពីខាងរតនគិរី-មណ្ឌលគិរីហ្នឹងវិញ?

សារឿន៖	ពួកហ្វូរ៉ូហ្នឹង វានៅមានពួកហ្នឹងមួយផ្នែកទៀត តែខ្ញុំអត់បានជ្រៅទេពួកហ្នឹង តែគ្រាន់តែខ្ញុំធ្លាប់ដឹងតាមតំបន់ហ្នឹងមាន៣ កំលាំង២ហ្នឹងចូលរួម ។

ដានី៖	កាលហ្នឹងកងពល៨០១នៅតាសារឿន(០៥) គាត់គ្រប់គ្រង?

សារឿន៖	នៅតា០៥ ដដែល ។

ដានី៖	បើភូមិភាគកណ្ដាល តាពក?

សារឿន៖	តាពក ។

ដានី៖	បើ៩២០ តា០៦ដដែល?

សារឿន៖	តា០៦ ។

ដានី៖	គេមានបង្កើតកងពលថ្មីទៀតដែលអត់ពេលហ្នឹង?

សារឿន៖	អត់មានទេ ។

ដានី៖	៨០២អីមានបង្កើតទេ?

សារឿន៖	៨០២កើតមកឆ្នាំ៨៥ហើយទេ កើតក្រោយទេ បំបែកចេញពី៨០១មកគេថា៨០២កើតក្រោយទេ ។

ដានី៖	ចុះ១០៥?

សារឿន៖	១០៥នេះឈ្មោះអង្គភាពដោយឡែក អត់មាននៅក្នុងកងពល៨០១ទេ នៅក្នុងតំបន់មណ្ឌលគិរី ។

ដានី៖	តែគាត់មកខាងហ្នឹងដែលអត់?

សារឿន៖	គាត់មកខាងហ្នឹងដែល តែគាត់នៅអូរធំលិច មុំ៣ នៅខាងលិចមុំ៣ ។

ដានី៖	អីចឹងបានន័យថាកំលាំង១០៥នៅក្នុងច្រក១០០១ដែលអត់?

សារឿន៖	នៅច្រក១០០១ជាប់ខ្សែ៩២០ ។

ដានី៖	១០៥មកជិតនាន់ជាមួយ៩២០ដែលអត់?

សារឿនៈ បាទ! មួយខែ្ស មួយសារ៩២០ ។

ដានីៈ តែជាកងពល ឬជាកងទ័ពតំបន់ ឬយ៉ាងម៉េច?

សារឿនៈ អានេះមិនមែនកងពលទេ ក្នុងកងទ័ពតំបន់មណ្ឌលគិរី ។ ព្រោះកាលហ្នឹងគេអត់ហៅកងពល គេហៅតែ១០៥ ។កងទ័ពរបស់ តាសារុន ។

ដានីៈ តាសារុន ណា?

សារឿនៈ ខ្មោចតាសារុន នៅ១០៥ហ្នឹង ។

ដានីៈ គាត់ទើបតែស្លាប់ទេ?

សារឿនៈ បាទ! ស្លាប់ប្រហែលមួយឆ្នាំ ។

ដានីៈ ព្រោះទើបតែជួបគាត់ឆ្នាំទៅ ។

សារឿនៈ តាសារុនហ្នឹង?

ដានីៈ សៅ សារុន ។

សារឿនៈ ប្រទ្បំ តាអន ស៊ុ ។

ដានីៈ តាអន ស៊ី គាត់ស្លាប់ហើយ?

សារឿនៈ តាអន ស៊ុ ប្រទ្បំ ។

ដានីៈ អីចឹងមណ្ឌលគិរី១០៥ហ្នឹងមិនមែនជាកងពលទេ?

សារឿនៈ អត់កងពលទេ តាមខ្ញុំដឹង គេបង្កើតម៉េចមិនដឹង ។

ដានីៈ ក្នុងហ្នឹងតាអន ស៊ី, តាសារុន ជាអ្នក?

សារឿនៈ គាត់អ្នកទទួលខុសត្រូវ៣-៤នាក់គ្នាគាត់ ។

ដានីៈ មានអីផ្សេង ពូអាចនឹកឃើញមានក្រុមណាដែលនៅខាង?

សារឿនៈ អត់មានទេ បើតាមខ្ញុំគិតទៅអត់មានក្រុមណាខុសពីទ្បាវក្រហម, ជីការហ្សូ៎ និងកងពល ប៉ុណ្ណឹងទេ ។ តែជីការហ្សូ៎ខ្ញុំឃើញតែមួយក្រុម ។ របៀបជាដាក់ទូតទំនាក់ទំនង បើពួកទ្បាវ ក្រហមនេះខ្ញុំបានមានតែកំលាំង ។

ដានីៈ អ្នកដែលគ្រប់គ្រងនៅ១០០១?

សារឿនៈ តាសុន សេន ។

ដានីៈ ពីណាទៀតក្រៅពីតាសុន សេន?

សារឿនៈ ក្រៅពីតាសុន សេន មានតាសារឿន ហ្នឹងឯង អត់មានពីណាទៀតទេ ព្រោះតាសារឿន គាត់ទទួលកងពលនៅហ្នឹងហើយ ។

ដានីៈ ចុះតាកែ ពក?

សារឿនៈ គាពក គាត់បន្ត្រប់ភូមិភាគរបស់គាត់ មួយភូមិភាគកណ្តាលគាត់ៗ អីចឹងគេអត់ចាត់តាំងជារូមអ្នកណាបន្តទៀតទេនៅក្នុង មានតាសុន សេន មួយគាត់ទទួលហើយ ។

ដានីៈ ចុះប្រជាជន?

សារឿនៈ ប្រជាជននៅក្នុងកងពល កងពលគ្រប់គ្រង ឧទាហរណ៍ថា កងពល ប្រធានកងពលនៅហ្នឹង អន្តភាពខ្ញុំ អ្នកទៅសមរភូមិ រៀបចំអ្នកណាសុខភាពអន់ឲ្យទទួលខុសត្រូវទៅ អ្នកពិការអីចឹង ទទួលខុសត្រូវប្រជាជននៅខាងក្រោយ ។

ដានីៈ លោកពូពេលហ្នឹងលោកពូនៅក្នុងកងរបស់តាកែវ ដដែល?

សារឿនៈ បាទ! ខ្ញុំនៅក្នុងកងតាកែវ ដដែល ។

ដានីៈ នៅកងពិសេសហ្នឹង?

សារឿនៈ បាទ! នៅកងពិសេសហ្នឹង ខ្ញុំចេញពីពិសេសរបស់តាកែវ ខ្ញុំទៅនៅ អាពិសេសរបស់ ៨០២ហ្នឹងគេយកមកធ្វើកងពិសេសរបស់តាកែវ ។

ដានីៈ កងពល៨០២?

សារឿនៈ ពិសេសលេខវរៈ៨០២ហ្នឹងគេយកមកធ្វើកងពិសេសរបស់តាកែវ ក្រោយមកបានគេឈប់ដាក់កងពិសេស គេដាក់ថាកងវរៈដូចធម្មតាទៅ ។

ដានីៈ ៨០២ហ្នឹង?

សារឿនៈ ៨០២របស់តាឡូច ។

ដានីៈ តាឡូចហ្នឹងដល់គាត់ទៅបាត់ ពីណាឡើងជំនួសគាត់?

សារឿនៈ គាត់ឡើងទៅបាត់ តាឆន ។

ដានីៈ តាឆន ប្អូនថ្លៃ ។

សារឿនៈ តាសុន សេនហ្នឹង តាឆន ប្រធានកងពល៨០២ ។ តាឆន ហើយនិងតាជឿន ដឹកនាំពេទ្យខ្ញុំក្រោយ ។

ដានីៈ យ៉ោក ជឿន ហ្នឹង?

សារឿនៈ យ៉ោក ជឿន គាត់នៅក្នុងជាមួយតាឆន ហ្នឹងដែរ ។ ក្រោយមកគេដកគាត់ពីកង៨០២ ហ្នឹងទៅដាក់ប្រធានពេទ្យម៉ិញ ។

ដានីៈ ដំបូងបំផុតតាម៉ុក គាត់មកអីចឹង ក្រោយមកតាសុន សេន មក តាម៉ុក គាត់ចេញពី ១០០១?

សារឿនៈ គាត់ចេញពី១០០១ មកនៅ១០០៣ ។

ដានីៈ គាត់មានដែលទៅវិញអត់?

សារឿនៈ ខ្ញុំអត់ដែលជួបសោះ ។

ដានីៈ គាត់ចេញឆ្នាំណា ដែលតាម៉ុក ចេញពី១០០១?

សារឿនៈ ខ្ញុំឆ្នាំ៨១ តែគាត់នៅចល័ត ។ គាត់ទៅពី១០០១ គាត់ទៅមើលចេញចូលៗ គាត់អត់ប្រាកដថានៅនឹងកន្លែងទេ ព្រោះអត់មានមូលដ្ឋានទេនៅហ្នឹង ។

ដានីៈ តាមមើលទៅតាម៉ុក គាត់នៅតែគ្រប់គ្រងធំដដែល?

សារឿនៈ គាត់នៅក្នុងចំណោមដឹកនាំកងទ័ពគាត់ហើយ ទោះបី តាសុន សេន សម្រាប់គេធ្វើការងារទូត ក្រៅប្រទេសក្នុងជួរគណៈរដ្ឋមន្ត្រី ។ តាម៉ុក បញ្ជាការកងទ័ពផ្ទាល់ ។

ដានីៈ ដូចថាពេលហ្នឹង១០០១ យើងមានការសហការណ៍តាមមុខសញ្ញា ដូចថាកងពល៨០១ ចាប់ផ្តើមធ្វើប្រតិបត្តិការពីត្រឹមណាៗ? កងពលរបស់ភូមិភាគពិសេសពីកន្លែងណាៗ? កងពល៩២០? មណ្ឌលគិរី៥០៥ លោកពូដឹងទេពេលហ្នឹង?

សារឿនៈ ខ្ញុំដឹង កងពល៨០១ធ្វើប៉ែកខាងលិចទន្លេមេគង្គនិងកំពង់ធំ ។

ដានីៈ ៨០១ប៉ែកខាងលិចទន្លេ និងកំពង់ធំ?

សារឿនៈ និងកំពង់ធំ ។

បូលីៈ បើយើងមើលផែនទីនៅខាងណាខ្លះប៉ែកខាងលិចទន្លេមេគង្គ?

សារឿនៈ ប៉ែកខាងលិចទន្លេរាប់តាំងពីព្រំដែនឡាវ កំពង់ស្រឡៅ មើលកំពង់ស្រឡៅមក ។

បូលីៈ នេះព្រំដែនឡាវយើងត្រឹមនេះ ។

សារឿនៈ មាត់ទន្លេល្ពៅហ្នឹងព្រំដែន ។

បូលីៈ នេះទន្លេល្ពៅ?

សារឿនៈ ទន្លេល្ពៅ មាត់ទន្លេល្ពៅហ្នឹងមកក្រោមចេះ ។

បូលីៈ មកចេះខាងកើត?

សារឿនៈ អានេះកើត ។

បូលីៈ បាទ! ខាងកើត?

សារឿនៈ ខាងកើតទន្លេ ។

បូលីៈ មិនមែនកើតទន្លេទេ ។ នេះទន្លេល្ពៅ នេះបានទន្លេមេគង្គ ។

សារឿនៈ មកចន្លោះនេះចេះ ធ្លាក់មកស្ទឹងត្រែង នេះមេគង្គ យើងនៅពីលិចមេគង្គ ធ្លាក់មកស្ទឹងត្រែង លិចមេគង្គ ។

បូលីៈ មកខាងក្រចេះយើង ។

សារឿនៈ ក្រចេះ៩២០ និងមណ្ឌលគិរី ។ ១០៥ក៏ក្រចេះ មណ្ឌលគិរីហ្នឹងដែរ ។

បូលីៈ ចុះរតនគិរី?

សារឿនៈ រតនគិរីរបស់តាធាត់ គេហៅតាធាត់ៗ មិនដឹងស្អីទេ ។

ដានីៈ តាធាត់ គាត់ធ្លាប់ជាគណៈភូមិភាគឥសាន ។

សារឿនៈ គណៈភូមិភាគឥសាន របស់កំលាំងតាធាត់ ។

ដានីៈ ក្នុងអីដែរនេះ?

សារឿនៈ នេះគេដាក់មូលដ្ឋានខ្ញុំមិនស្គាល់ដែរ ។

ដានីៈ តែក្នុងប្រក១០០១ដែរ?

សារឿនៈ ប្រក១០០១ដែរ ។

ដានីៈ មានកំលាំងរបស់តាធាត់ មួយទៀត?

សារឿនៈ របស់តាធាត់ ។

ដានីៈ ជាកំលាំងហ្នឹងជាកងពល ជាវរសេនាធំ ឬយ៉ាងម៉េច?

សារឿនៈ អត់ទេ គេថាកំលាំងមូលដ្ឋានរបស់ភូមិភាគតែម្តង ។

ដានីៈ តាធាត់ របស់ភូមិភាគឥសាន ។ អីចឹងរតនគិរីរបស់តាធាត់?

សារឿនៈ រតនគិរីតាធាត់ ត្រូវហើយ ។ មណ្ឌលគិរីតាសាន និង១០៥ ។

ដានីៈ ក្រចេះ ។ បើខាង៨០១ស៊ឹងត្រែង ។

សារឿនៈ ខ្ញុំ៨០១ ស៊ឹងត្រែង កំពង់ធំ ទៅយើងលូកទៅមុខកំពូល ។

ដានីៈ លូកទៅខាងមុខកំពូលទៀត?

សារឿនៈ បាទ! មុខកំពូលទៀត ។

ដានីៈ ចូលជិតដល់ភ្នំពេញហើយអីចឹង ខេត្តកណ្តាល?

សារឿនៈ ថាទៅវ៉ៃ កងពល៨០១វ៉ៃឆ្នាំប៉ុន្មាន វ៉ៃដល់ទំនប់សាឡាងនៅព្រែកក្តាម ។

ដានីៈ ខាងព្រះវិហារអត់មានទេ?

សារឿនៈ ព្រះវិហារក៏ពួកខ្ញុំ ចុះកំពង់ស្រឡៅហ្នឹងមិនទឹកដីព្រះវិហារ នេះមុំពទន្លេល្ពៅ ទឹកដីព្រះវិហារ ហ្នឹងដាក់តាមវរសេនាតូច វរសេនាធំ ។

ដានីៈ ខាងភូមិភាគកណ្តាលរបស់កែវ ពក វិញ?

សារឿនៈ របស់កែវ ពក គាត់ចូលទៅកំពង់ចាម គ្នាគាត់ភូមិភាគកណ្តាលទៅ ។

ដានីៈ ចុះកំពង់ធំអត់ទេ?

សារឿនៈ កំពង់ធំពួកខ្ញុំដែរ ដល់ក្រោយមកបង្កើត៨០២ ឲ្យ៨០២ទទួលដាច់ តែកាលនៅកងពល ចំរុះពួកខ្ញុំដែរ ត្រឹមឆ្នាំ៨៥ ។

ដានី៖ អ៊ីចឹងភូមិភាគកណ្ដាលរបស់កែវ ពក តែដីកំពង់ចាមមួយទេ?

សារឿន៖ បាទ! តែដីកំពង់ចាមទេ ។

ដានី៖ អ៊ីចឹង១០០១វិសាលភាពវាមានកំពង់ធំ, កំពង់ចាម, ក្រចេះ, ស្ទឹងត្រែង, រតនគិរី, មណ្ឌលគិរី ហើយនិងព្រះវិហារមួយចំណែក?

សារឿន៖ ព្រះវិហារមួយចំណែក ។

ដានី៖ ហើយលោកពូថាចូលដល់មុខកំពូល ដល់អីណាទៀត យ៉ាងម៉េចទៅ?

សារឿន៖ អាហ្នឹងនៅក្នុងកងពលខ្ញុំ ចូលទៅវ៉ៃព្រែកក្ដាមម្ដង ។

បូលី៖ មុខកំពូលវានៅខេត្តកណ្ដាល ។

សារឿន៖ នៅខេត្តកណ្ដាល ពួកខ្ញុំនៅតាមបឹង មានកំលាំងគេចល័តតាមបឹង ទៅនៅពួនក្នុងបឹង ទំនាក់ទំនងតាមរយៈប្រជាពលរដ្ឋចេញ-ចូលតាមស្រែប្រាំង នៅពួនមួយក្រុមៗ ។

ដានី៖ លោកពូកន្លែង១០០១នេះទន្លេល្អៅ មកដលនេះ ។ ១០០១ គេចង់សំដៅទៅលើច្រកទេ តែកងទ័ពដែលចុះធ្វើសកម្មភាពចូលមកម៉ិញ ដូចរៀបរាប់មកម៉ិញអីចឹង?

សារឿន៖ បាទ!

ដានី៖ ពួក១០០១ ។

បូលី៖ ត្រឹមនេះកាត់មកចេះ១០០១?

ដានី៖ បាទ!

បូលី៖ ដល់១០០៣ មកនេះវិញ?

ដានី៖ ហ្នឹងហើយ ។

បូលី៖ ទៅចេះវិញ?

សារឿន៖ ១០០៣រាប់ស្រុកដាំក្សាន្ត ។

ដានី៖ អ៊ីចឹងលោកពូយើងនៅហ្នឹងរហូតដល់ពេលណាបានដកចេញ?

សារឿន៖ ឆ្នាំ៨៤ ។

ដានី៖ ឆ្នាំ៨៤យ៉ាងម៉េចទៅពូ?

សារឿន៖ ឆ្នាំ៨៤ រស់នៅកន្លែងហ្នឹងវៀតណាមវ៉ៃ ដល់វៀតណាមវ៉ៃទៅទប់ទល់អត់បាននាំប្រពន្ធកូនមីងៗដកថយមកនៅ១០០៣ដូចគ្នា មកនៅជុំជាមួយតាម៉ុក ។

ដានី៖ តាសុន សេន គាត់ទៅណាវិញ?

សារឿន៖ តាសុន សេន ក៏គាត់មកនៅហ្នឹងដែរ តែគាត់គ្រប់គ្រង១០០១ ទោះបីមកនៅក្នុងភូមិសាស្ត្រតែមួយ តែគាត់នៅតែគ្រប់គ្រងកំលាំង១០០១ហ្នឹងដដែល ។

ដានី៖ គាត់មកចេញពីច្រក១០០១ មកនៅ១០០៣ ប៉ុន្តែគាត់គ្រប់គ្រងកំលាំងដែលមកពី១០០១ទាំងអស់ មក១០០៣គាត់គ្រប់គ្រងដដែល?

សារឿន៖ គាត់គ្រប់គ្រងហ្នឹងដែរ ។

ដានី៖ អ៊ីចឹងយើងចេញពី១០០១មកនៅ១០០៣ យើងនៅកន្លែងណាទៅ?

សារឿន៖ ចេញពី១០០១ មក១០០៣ អូរគ្រាវក៏ខ្ញុំធ្លាប់នៅ ។ ចងកក៏ធ្លាប់នៅ លើទឹកដីថៃ ។ គ-៧ក៏ធ្លាប់នៅ រូបដងទង់នោះក៏ធ្លាប់នៅ ស៊ឹងចាន់ ។ អ៊ីចឹងរស់នៅមិនអីប្រាកដទេ កន្លះឆ្នាំ មួយឆ្នាំចល័ត ។

ដានី៖ លោកពូពេលដែលយើងមកចេញពី១០០១ មក១០០៣ ចុះ១០០២យើងបាត់តាំងពីអន្លាល់ទៅ?

សារឿន៖ ១០០២នៅកំលាំងកងពលតាហឿន ហ្នឹង គាត់នៅគ្រប់គ្រងដដែល១០០២ ។

ដានី៖ តែយើងនៅមានជា១០០២ទៀតឬអត់ទេ?

សារឿន៖ ដល់ពេលនោះចេះ ឆ្នាំ៨៤ហ្នឹងតែមួយទេ វៀតណាមវៃមួយសារហ្នឹងវៃ១០០២ខូចមុនរត់ទៅនៅហ្នឹងដូចគ្នា១០០៣ ហើយក្រោយមកបានបកទៅវៃ១០០១ហ្នឹងដាច់មួយទៀត អ៊ីចឹងមកនៅជុំគ្នាតែ១០០៣តែមួយ ។

ដានី៖ អ៊ីចឹង១០០២គេវៃដាច់មុនគេ?

សារឿន៖ ១០០២វៃដាច់ ។

ដានី៖ ច្រកកន្លែងណា?

សារឿន៖ ច្រកជប់រុននេះ ។

ដានី៖ ជប់រុននេះហ្នឹង?

សារឿន៖ បាទ ។

ដានី៖ កងពលណានៅកន្លែងហ្នឹង?

សារឿន៖ កងពលរបស់តាហឿន ។

បូលី៖ ៦១២?

សារឿន៖ ៦១២ កងពលរបស់តាស្អីគេដែលគេដកទៅលិច ភ្លេចឈ្មោះគាត់ហើយ ។

ដានី៖ តាឈាន?

សារឿន៖ មិនមែនទេ ។ តាឈាន ប៉ិគក់ ត្រូវហើយ និងតាអីគេមួយ ។

បូលី៖ តាឈាន ប៉ិគក់ ។

សារឿន៖ គាត់នៅសំឡូតមិនដឹងស្លាប់ឬនៅ ។

ដានីៈ តាណា?

សារឿនៈ តាឈាន ទៅនៅសំឡូត គេហៅតាឈាន ប៊ិគក់ ទៅដល់ហ្នឹងមិនដឹងឈ្មោះអី ។

ដានីៈ ឥឡូវគាត់នៅតា៎?

សារឿនៈ ដូចនៅទេ តាឈាន ហ្នឹងគាត់ទៅនៅសំឡូត ។

ដានីៈ អីចឹងនៅច្រក១០០២មានតែកងពល តាហឿន មួយទេ?

សារឿនៈ បាទ! មានតែមួយទេរួម ។

ដានីៈ ម៉េចបានគេវៃដាច់ហ្នឹងមុនគេ? កន្លែងហ្នឹងទីតាំងវាយ៉ាងម៉េច?

សារឿនៈ កន្លែងហ្នឹងបុកច្រកព្រះប្រឡាយ ច្រកជប់រុន ។

ដានីៈ ដល់ពេលគេបុកដាច់រត់ទៅនៅណា?

សារឿនៈ បុកដាច់ធ្លាក់ទៅនៅដំកង់ នៅខាងកើតក្បាលទឹកចាន់ ។

ដានីៈ កន្លែងណាបើយើងមើលតាមភូមិសាស្ត្រ?

សារឿនៈ នៅស្រុកនេះអត់មានទេ នៅទឹកដីថៃទាំងអស់ ។

ដានីៈ ក្នុងស្រុកអីគេ? កន្លែងដំកង់?

សារឿនៈ ដំកង់នៅក្នុងស្រុកការស៊ិន ។

ដានីៈ តែបើយើងទល់មកស្រុកខ្មែរយើង?

សារឿនៈ ស្រុកខ្មែរយើងទឹកដីស្រុកត្រពាំងប្រាសាទហ្នឹង ។

ដានីៈ តែក្នុងឃុំអី?

សារឿនៈ ឃុំទំនប់ដាច់ក៏មាន ឃុំអូរស្មាយក៏មាន ។

ដានីៈ កន្លែងដំកង់ កន្លែងអូរត្រាវ បើទល់មុខភូមិអីទៅ?

បូលីៈ បើជប់មួយើងនៅទល់មុខជាមួយជាំស្រង៉ាំ ។

សារឿនៈ ហ្នឹងនៅខាងកើត ខាងជើងជាំទៀតនោះ ។

ដានីៈ ខាងណាជាំទៀតទៅ?

បូលីៈ ខាងជើងមានន័យថាមកខាងនេះ ។

សារឿនៈ វានៅលើទឹកដីថៃចេះ ។

បូលីៈ ទឹកដីថៃ ប៉ុន្តែវានៅទល់មុខជាមួយជាំ?

សារឿនៈ ជាំ ។

បូលីៈ ជប់មួហ្នឹងអ៎ំ?

សារឿនៈ បាទ!

បូលីៈ ចុះស្ទឹងចាន់នៅទល់មុខជាមួយអីគេ?

សារឿនៈ ស្ទឹងចាន់មកស្របនឹងគ្នាទៅក្នុងទៅទឹកដីថៃក្នុងទៀតទៅ តែងាកមកខាងជើងនេះតិចវិញ ។

ដានីៈ ងាកមកខាងជើង ងាកមកត្រពាំងប្រាសាទ ឬងាកទៅណា?

សារឿនៈ ងាកមកត្រពាំងប្រាសាទ ងាកមកខាងត្រពាំងប្រាសាទយើងនេះ ច្រកអូរស្មាយវិញ ។

ដានីៈ ច្រកអូរស្មាយ?

សារឿនៈ ក្នុងឃុំអូរស្មាយវិញ ។

បូលីៈ បើយើងថាជប់ម្ទូនៅម្តុំនេះចុះ នៅទល់មុខជាមួយជាំ អីចឹងបើអូរត្រាវវាងាកខាងនេះ ។

សារឿនៈ ខាងមកចឹង ។

បូលីៈ អូរត្រាវងាកមកនេះទៀត?

សារឿនៈ បាទ!

បូលីៈ ចុះស្ទឹងចាន់?

សារឿនៈ ស្ទឹងចាន់មកខាងក្រោយអូរត្រាវនេះតិចទៀត ។

បូលីៈ ងាកមកអូរត្រាវទៀត?

សារឿនៈ ជួរពីលិចហ្នឹងទៀត ។

បូលីៈ អីចឹងឆ្ងាយជាងហ្នឹងទៀត?

សារឿនៈ ឆ្ងាយជាងហ្នឹងទៀត ។

បូលីៈ ចុះដងទង់ម្តុំណា?

សារឿនៈ ដងទង់ ស្ទឹងចាន់តែមួយ គ្រាន់តែយើងរស់នៅក្បាលស្ទឹងចាន់ ធ្លាក់មកក្រោមដងទង់
បន្ទាយមេព្រៃទាហាន ខ្មែរយើងចេះតែហៅដងទង់ៗ ។

បូលីៈ ព្រោះមានដងវាខ្ពស់ទៅលើ?

សារឿនៈ មានដងទង់ជាតិគេ ។

ដានីៈ បន្ទាយមេព្រៃទាហានរបស់ថៃ?

សារឿនៈ មេព្រៃថៃ យើងចេញចូលស្ពានណាក៏បានដែរ ។

បូលីៈ ជប់ម្ទូ, អូរត្រាវ ហើយនិងស្ទឹងចាន់-ដងទង់នេះ ។ មានអីទៀតទេតំបន់?

សារឿនៈ មានចងកមួយទៀតនៅក្នុង ។

បូលីៈ ចងកនៅម្តុំណា?

សារឿនៈ ចងកហួសអូរត្រាវដីប្រហែល៥-៦គីឡូ ប្រឡោះអូរត្រាវ ប្រឡោះដងទង់ វានៅប្រឡោះ
អីចឹង ។

បូលីៈ អាចម្តុំនេះចង់ក ។

សារឿនៈ អាហ្នឹងមានស្ទឹងអូរមួយក៏ប្រជាជនគេដាក់នៅហ្នឹងដែរ ថៃអនុញ្ញាតិឲ្យនៅ ។

ដានីៈ ក្នុងដីរបស់ថៃទេ?

សារឿនៈ ក្នុងដីរបស់ថៃ ។

ដានីៈ ហ្នឹងក្រុមរបស់ពូដែល១០០១នៅ ដូចពូរៀបរាប់មានប្រសាសន៍មុិញ ១០០១ដែលផ្លាស់មកនៅក្នុងកន្លែងហ្នឹង?

សារឿនៈ ក្នុងតំបន់ហ្នឹង ។

ដានីៈ ១០០៣?

សារឿនៈ បាទ! ហើយកំលាំង១០០៣ក៏នៅមិនឆ្ងាយពីគ្នាប៉ុន្មានដែរ ។

ដានីៈ ១០០៣នៅណាទៅ?

សារឿនៈ នៅមួយខ្សែហ្នឹងទាំងអស់គ្នា នៅ៤០ ។

ដានីៈ ៤០នៅណា?

សារឿនៈ ៤០នៅទល់អន្លង់វែងដែរ នៅទល់មុខប្រោក ។

បូលីៈ ប្រោកម្តុំណាទៅជាមួយយើង?

សារឿនៈ ប្រោកខាងកើតអន្លង់វែងបន្តិច ។

បូលីៈ នេះយើងដាំ?

សារឿនៈ នៅម្តុំនេះ មកខាងនេះ ។

បូលីៈ នេះប្រោក?

សារឿនៈ បាទ មកខាងនេះ ប្រោកនៅខាងនេះ ។

បូលីៈ ដីថៃដែរ?

សារឿនៈ ប្រោកក្បាលមកនេះ ប្រោកដីខ្មែរ ។

ដានីៈ ជាប់ជាមួយខាង?

សារឿនៈ ខាងកើតអន្លង់វែង ដី៤-១០គីឡូមក កន្លែងផ្ទះប៉ុល ពត ហ្នឹង ។

បូលីៈ ក្បាលទន្សោង?

សារឿនៈ ខាងកើតក្បាលទន្សោងហ្នឹងបន្តិច ។

ដានីៈ ពើយតាឌី?

សារឿនៈ អត់មានពើយតាឌី ។

ដានីៈ ពើយតារូន?

សារឿនៈ ពើយគារួននៅខាងកើតហ្នឹងទៀត ហ្នឹងមិនទាន់ដល់ផ្ទះប៉ុល ពតផង ។

ដានីៈ ហ្នឹងអត់ទាន់ដល់ក្បាលទន្សោង?

សារឿនៈ អត់ទាន់ដល់ក្បាលទន្សោងផងហ្នឹង ។

បូលីៈ បានន័យថាប្រោកនៅខាងកើតក្បាលទន្សោងហ្នឹងទៀត?

សារឿនៈ បាទ! ប្រោកនៅខាងកើតក្បាលទន្សោងហ្នឹងទៀត ហើយចំប្រោកហ្នឹងទៅលិចចេះទៅ៤០ ៤០ហ្នឹងគេហៅកន្លែងតាវ៉ែន កូនប្រសារតាម៉ុក នៅ ។

បូលីៈ ៤០ហ្នឹងជាអ្វី?

សារឿនៈ ជាតំបន់ កន្លែងជំរំតែម្តង ជំរំកងទ័ពរបស់ខ្មែរក្រហម ៤០ហ្នឹង ។

បូលីៈ ក្នុងដីថៃ?

សារឿនៈ ក្នុងដីថៃ ។

ដានីៈ អាហ្នឹងកំលាំង១០០៣?

សារឿនៈ កំលាំង១០០៣ រួចផុតពី១០០៣ មានកំលាំង១០០១ ជួនកាលផុតពី១០០១ទៅ កំលាំង១០០៣នៅប្រឡោះកណ្តាលបន្តគ្នាទៀត រាងស៊ីវាក ៗ ។

ដានីៈ ក្រុម១០០២នៅណាវិញទៅ?

សារឿនៈ ក្រុម១០០២ក៏នៅក្នុងចន្លោះប្រឡាយជាមួយគ្នាហ្នឹងដែរ ។

ដានីៈ នៅណា?

សារឿនៈ នៅតំបន់ហ្នឹងតែមួយដែរ ជួនកាលនៅខាងត្បូងអូរគ្រាវ ខាងជើងអូរគ្រាវអីចឹង ។

ដានីៈ តែកំលាំងទាំងអស់ហ្នឹងអត់ចូលគ្នាទេ?

សារឿនៈ អត់ចូលទេ ។

ដានីៈ ពួកទាហានមកពីម្តុំណានៅតែម្តុំៗ?

សារឿនៈ នៅតែម្តុំៗគ្នាយើងអីចឹងទៅ រួចគេនៅម្តុំគ្នាគេ ជិតគ្នា ដាច់គ្នា ៥០-១០០ម៉ែត្រ ។

បូលីៈ វាគ្មានអីជាច្បាស់លាស់ទេនិយាយទៅ វានៅម្តុំគ្នាតែបើឲ្យចែកទឹកដីគ្នាឲ្យច្បាស់លាស់អត់ មានទេ ។

សារឿនៈ អត់មានទេ ។

បូលីៈ ជួនកាលម្តុំនេះៗ ជួនកាលអានេះនៅម្តុំហ្នឹងក៏ថាបាន ។

សារឿនៈ នៅរំលងគ្នា ។

បូលីៈ ដុំវិញហ្នឹង?

សារឿនៈ ជុំវិញហ្នឹងទៅ ។ បើអូរត្រាវប៉ុន្មានអន្តភាពក្រោយមកគេធ្វើជំរំ គេដកធ្វើជំរំ កងទ័ពខ្មែរក្រហមផ្លាស់ចេញអស់ទៅ គេដកធ្វើជំរំ ។

បូលីៈ ពីណាដកធ្វើជំរំ?

សារឿនៈ កាលនោះកងទ័ពខ្មែរក្រហមដកទៅគេបង្កើតជំរំមួយ គេហៅជំរំអូរត្រាវ អីចឹងអត់មានកំលាំងរបស់បុគ្គលណាទេ ពួកខ្មែរក្រហមអត់មានទេ មានកំលាំងខ្មែរក្រហម ប៉ារ៉ាសេរីទៅនៅរួមគ្នា គេហៅថាជំរំរបស់អង្គការ ។

ដានីៈ បានន័យថាខាងម្ចាស់ជំនួយ ខាងបរទេសគេទាមទារឲ្យបង្កើតជំរំមួយ?

សារឿនៈ គេបង្កើតជំរំ អ្នកដែលកងទ័ពខ្មែរក្រហមគេអត់ឲ្យនៅក្នុងហ្នឹងទេ អ្នកស្ម័គ្រចិត្តទៅនៅជារបៀបអ្នកជំរំទៅចុះ តែបើកងទ័ពគេសុទ្ធគេអត់ទៅនៅទេ គេទៅតំបន់ខាងជើង គេអត់ទៅទេ នៅក្នុងកងពលគេវិញ គ្នាគេ ។

បូលីៈ គេទៅនៅកៀកព្រំដែនជាងប្មុយ៉ាងម៉េច?

សារឿនៈ អត់កៀកទេ នៅ១-២គីឡូពីអូរត្រាវក៏គេនៅ តែគេអត់នៅក្នុងជំរំទេ ។

បូលីៈ បានន័យថាជំរំអូរត្រាវដែលពីមុនខ្មែរក្រហមកាន់កាប់ ត្រូវបានខាងអង្គការសហប្រជាជាតិកាន់កាប់ហើយ?

សារឿនៈ និយាយអីចឹង ឆ្នាំ៩០មុនមានកិច្ចព្រមព្រៀងប៉ារីសគេចុះមកស្រុកខ្មែរ ហើយមកនៅតាមបន្ទាត់ព្រំដែន ចាប់អីអន្លង់វែងមកដល់យើងហ្នឹង ឆ្នាំ៩០ សភាពការណ៍អស់អីហើយ បានគេបង្កើតជំរំហ្នឹង ។

បូលីៈ អូរត្រាវបង្កើតឆ្នាំណា?

សារឿនៈ ខ្ទង់ឆ្នាំ៩០ ព្រោះអ្នកជំរំខ្មែរក្រហមចុះមកក្រោមអស់ ឃើញអ្នកជំរំខ្មែរក្រហមដែលរត់ទៅនៅអូរត្រាវវិញ រត់ទៅរពុយៗ រត់ពីក្រោមស្រុកខ្មែរយើងទៅនៅជំរំហ្នឹង ។

បូលីៈ ខ្មែរក្រហមរត់ទៅ?

សារឿនៈ រត់ទៅ ។

បូលីៈ មុនពេលដែលបង្កើតឆ្នាំ៩០ហ្នឹងគេហៅអូរត្រាវដែល គ្រាន់តែខ្មែរក្រហមនៅ?

សារឿនៈ ខ្មែរក្រហនៅ ដល់ខ្មែរក្រហមគេដឹកពីអូរត្រាវចុះមកក្រោមមក ពី៨០ ពីចងក ដឹកមកដាក់តាមបន្ទាត់ព្រំដែននេះអស់ ហើយវាមានអ្នកខ្លះអត់មក ប្រជាជនអីហ្នឹង បានពួកអង្គការគេបង្កើតជំរំហ្នឹងហើយមានប្រជាជន យើងនៅក្រោមវាលំបាកពេក ដាច់ទឹក ដាច់ស្បៀងដឹកមកអត់ទាន់ ធ្វើផ្លូវអន្លង់វែងអត់ទាន់ហើយ រត់ទៅនៅជំរំហ្នឹងវិញ បានជាជំរំអូរត្រាវមួយមក ។

បូលីៈ	តាមខ្ញុំដឹងដំរំហ្នឹងបិទវិញឆ្នាំ៩២ ខួន់ខែ៩ ថ្ងៃ២៨ ខែ៩ ៩២បិទវិញ បានន័យថាធ្វើមាតុភូមិនិវត្តន៍មកខាងក្នុងអស់ហើយ ដែលប្រជាជនសាមញ្ញ ខ្មែរក្រហមចុះមកអន្លង់វែងត្រពាំងប្រាសាទអស់ហើយ ។

សារឿនៈ	អន្លង់វែង ត្រពាំងប្រាសាទ ។

បូលីៈ	នៅខាងដីថៃលែងមានទីតាំងខ្មែរក្រហមទៀតហើយ គឺថៃបិទហើយពេលហ្នឹង ព្រោះកិច្ចព្រមព្រៀងប៉ារីសគំរូវឲ្យថៃលែងគាំទ្រ និងផ្តល់ដីឲ្យខ្មែរក្រហមនៅទៀតហើយ ។

សារឿនៈ	ក្រោយកិច្ចព្រមព្រៀងហើយ ។

បូលីៈ	មុនហ្នឹង ខ្ញុំចង់សំដៅមុនហ្នឹង មុនកិច្ចព្រមព្រៀង៩១ អូរត្រាវខ្មែរក្រហមនៅកាន់កាប់មែន?

សារឿនៈ	មុនហ្នឹងខួង់ឆ្នាំ៨៧-៨៨-៨៩ជិតដល់៩០ នៅខ្មែរក្រហមនៅទេ ដល់ចូលឆ្នាំ៩០ខ្មែរក្រហមត្រូវការបញ្ជូនអង្គភាពខ្មែរក្រហមមកនៅស្រុកខ្មែរ ។

ដានីៈ	ខ្ញុំយល់ចេះខុសត្រូវចាំជួយកែខ្ញុំ ពេលហ្នឹងពេលដែលកង់ទ័ពវៀតណាមដកទៅឆ្នាំ៨៩ ខាងខ្មែរក្រហមវ៉ៃកាន់កាប់បានតំបន់អន្លង់វែង នៅខាងត្រពាំងប្រាសាទហ្នឹង ពេលដែលវ៉ៃបានហើយបញ្ជូនកងទ័ព បញ្ជូនគ្រួសារកងទ័ពចុះមក អ៊ីចឹងបានន័យថាពីឆ្នាំ៩០ទៅជំរំអូរត្រាវគាត់លែងកាន់កាប់ អ៊ីចឹងត្រូវទេ?

សារឿនៈ	បាទ! ត្រូវហើយ គេបង្កើតទៅជាជំរំរបស់អង្គការកាកបាទក្រហម ហើយបានមានមនុស្សចេះតែចូលទៅរស់នៅ ។

បូលីៈ	ចុះមុនហ្នឹង មុនពេលដែលខ្មែរក្រហមចុះមកអន្លង់វែង ត្រពាំងប្រាសាទ តើមានអង្គការមកទេ?

សារឿនៈ	អត់ទាន់មានទេ កាលពីមុនខ្មែរក្រហមចុះមកមានតែពេទ្យបារាំង ពេទ្យកាកបាទក្រហមគេមកមើលអ្នកជំងឺតូចតាចលិចកើត ។

បូលីៈ	តែអ្នកគ្រប់គ្រងគឺខ្មែរក្រហមដដែល?

សារឿនៈ	គ្រប់គ្រងខ្មែរក្រហម ។

ដានីៈ	ជំនួយអត់ទាន់មានទេ? ជំនួយជាថ្នាំពេទ្យ គ្រឿង ជាម្ហូប ជាស្បៀង ជាអាហារផ្សេងៗ?

សារឿនៈ	ជំនួយម្តងយាមទេ ជួនកាលគេនឹកឃើញយើងមកបើកផ្តល់ឲ្យ គេបើកឲ្យមួយឡាន បើកឲ្យអ្នកនៅតំបន់ខ្មែរក្រហមហ្នឹងទៅ ។

បូលីៈ	តែឲ្យតែស្ត្រីនិងកុមារទេ?

សារឿនៈ	ឲ្យតែស្ត្រីនិងកុមារទេ កងទ័ពអត់ឲ្យទេ ។

បូលីៈ ព្រោះគេចាត់ទុកថាកង់ទ័ពហ្នឹងអ្នកច្បាំង គេមិនឲ្យអ្នកច្បាំងទេ ។

សារឿនៈ ឲ្យតែស្ត្រី និងកុមារតូចតាច ។ ឲ្យហើយប្ដីឡើងពីមុខស៊ីទាំងអស់គ្នា ។

បូលីៈ អ៊ីចឹងពេលដែលវៀតណាមធ្វើប្រតិបត្តិការបោសសំអាតតាមព្រំដែននេះ បោសសំអាតទៅខ្មែរក្រហមលែងមានដីខ្មែរនៅទៀតហើយ គឺនាំគ្នារត់ទៅនៅដីថៃ?

សារឿនៈ នៅលើទឹកដីថៃទាំងអស់ ។

បូលីៈ ទាំងអស់នៅតាមបណ្ដោយព្រំដែននេះ?

សារឿនៈ តាមបណ្ដោយព្រំដែន ។

បូលីៈ ដោយយើងមិនបាច់និយាយខាងណា យើងនិយាយត្រឹមខាងនេះ គឺថា១០០៣នេះមកនៅតាមដូចជាជប់ម្ហូ, ស៊ឹងចាន់, អូរត្រាវ, ប្រកអូរ៥០, ៤០អីចឹងទៅ ។

សារឿនៈ បាទ! មកនៅតាមហ្នឹងទាំងអស់ ។

បូលីៈ ដងទង់ ស៊ឹងចាន់ ។

សារឿនៈ ដងទង់ ស៊ឹងចាន់អីចឹងទៅ ។

បូលីៈ ខៃដន, ឡូនស៊ុង អីចឹងទៅ ។

សារឿនៈ ខៃដន, ឡូនស៊ុងនៅរយៈពេលខ្លីទេ ។

បូលីៈ តែសុទ្ធតែនៅដីថៃទាំងអស់?

សារឿនៈ សុទ្ធតែលើទឹកដីថៃទាំងអស់ ។

បូលីៈ ហើយក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម?

សារឿនៈ បាទ! ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។

បូលីៈ ចន្លោះយើងថាពីដើម៨៥ មកចុង៨៩ ។

សារឿនៈ បាទ!

បូលីៈ ក្រោយពីវៀតណាមដកទៅចុង៨៩ បានខ្មែរក្រហមវ៉ៃយកដីខ្មែរវិញ ហើយមករស់នៅលើដីខ្មែរវិញ ហ្នឹងនាំគ្នាប្រមូលកំលាំងចុះពីលើភ្នំមកហើយ ។

សារឿនៈ នាំគ្នាធ្វើផ្លូវសិន ។

បូលីៈ លើផ្លូវសិន ។

សារឿនៈ ផ្លូវអន្លង់វែងហ្នឹង ។

បូលីៈ ដាំស្រងាំ ។

សារឿនៈ ធ្វើផ្លូវដាំស្រងាំហ្នឹងធ្វើចុះមក បានផ្លូវហើយបានដឹក គេមានឡានគេ ឡានចិនជួយដឹកចុះមក តែបើប្រកនេះដើរចុះមក ។

បូលីៈ ពេលហ្នឹងបានអូរត្រាវហ្នឹងត្រូវបានគេ អង្គការសហប្រជាជាតិបង្កើតជាជំរំជនភៀសខ្លួនសំរាប់ជនស៊ីវិល ដែលមិនព្រម ឬមិនចង់មកជាមួយខ្មែរក្រហម ។

សារឿនៈ ហ្នឹងហើយ ត្រូវហើយ ។

បូលីៈ អីចឹងអ្នកដែលមិនចង់មក អ្នកដែលរត់មកវិញគឺមកនៅក្នុងអូរត្រាវ ក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ មិនមែនខ្មែរក្រហមទៀតទេ?

សារឿនៈ អត់មានទេ អត់មានខ្មែរក្រហមទៀតទេ ។

បូលីៈ តែយើងដៅមិនដឹងទេ ព្រោះយើងអត់មានផែនទី យើងអត់ដឹងថាមួយណានៅត្រង់ណាៗ គ្រាន់តែយើងដឹងថាជប់ម្ទូ, អូរត្រាវ វានៅជន្លៀសៗគ្នាតិចៗ ។

សារឿនៈ ចន្លោះៗគ្នាតិចតួចៗ តែឡូតែមុខចំណោមប្រទេសថៃមើលស្រែប្រិយ៍, អូរថ្កូវ ។ ជប់ម្ទូនៅបែកខាងនេះ ។

បូលីៈ តែបើយើងមើលផែនទី យើងអាចនិយាយបានថា កន្លែងដែលខ្មែរក្រហមរស់នៅទាំងអស់ហ្នឹងដែលយើងរៀបរាប់អំបាញ់មិញ វានៅទល់មុខអន្លង់វែង ត្រពាំងប្រាសាទ ជាំក្សាន្តហ្នឹងទេ?

សារឿនៈ មួយខ្សែហ្នឹងទាំងអស់ ។

បូលីៈ អត់ដល់ជាំក្សាន្តទេ?

សារឿនៈ អត់ដល់ជាំក្សាន្តទេ ត្រឹមជប់រុនមកចេះដល់អន្លង់វែង ។

បូលីៈ គឺវានៅទល់មុខហ្នឹង?

ដានីៈ ជប់រុនទៅអន្លង់វែង?

សារឿនៈ បាទ! ពីជប់រុនទៅអន្លង់វែង ចន្លោះប៉ុណ្ណឹង ។

ដានីៈ ចុះទំនប់ដាច់យើងនេះអត់ទេ?

សារឿនៈ ចុះជប់រុននៅខាងនេះទំនប់ដាច់ ។

បូលីៈ ទំនប់ដាច់វាចុះមកក្រោមហើយ ។

សារឿនៈ ចុះមកក្រោមហើយ ពីជប់រុននោះ ហើយខ្សែបន្ទាប់ព្រំដែនហ្នឹង ។

ដានីៈ ទៅចេះវិញ ។

សារឿនៈ ជាំស្វាសុទ្ធតែដីពួកខ្មែរក្រហមនៅ ។

បូលីៈ ខាងលិច?

សារឿនៈ បាទ! ទៅចេះទៅ ។

ដានីៈ ជប់រុន, ចម្ការម្ទេសអីហ្នឹង?

សារឿនៈ មកចេះ ហ្នឹងហើយសុទ្ធតែតំបន់ខ្មែរក្រហមនៅ លើទឹកដីថៃទាំងអស់ ។
បូលីៈ ខុសគ្នាយ៉ាងម៉េចរវាងជប់រុន ហើយនិងជាំស្វា?
សារឿនៈ ខុសគ្នាទៅក្រោយ ។
បូលីៈ ពីណាក្រោយ ពីណាមុខ?
សារឿនៈ ជប់រុននៅមុខ នៅលើបន្ទាត់ព្រំដែន ជាំស្វាចូលទៅជ្រៅលើទឹកដីថៃ ។
បូលីៈ ទល់មុខជាមួយជប់រុន?
សារឿនៈ វានៅទន្ទឹមគ្នាពីក្រោយពីមុខ ។
ដានីៈ បានន័យថា ពីមុខ ពីក្រោយចេះ?
សារឿនៈ បាទ! ឧទាហរណ៍ថាជប់រុននៅចេះ ជាំស្វានៅចេះ ។
ដានីៈ ចូលជ្រៅលើទឹកដីថៃ?
សារឿនៈ ចូលលើទឹកដីថៃ ។
ដានីៈ អីចឹងជាំស្វាហ្នឹងឈ្មោះថៃទេ?
សារឿនៈ ឈ្មោះរបស់ថៃទេ តែជំនាន់ហ្នឹងខ្មែរក្រហមរស់នៅតាមភូមិហ្នឹង ភូមិថៃ ចំការថៃគេបោះបង់ចោល ។
ដានីៈ ជប់រុនហ្នឹងឈ្មោះខ្មែរយើង ឬឈ្មោះថៃ?
សារឿនៈ ឈ្មោះខ្មែរ ។
ដានីៈ បន្ទាត់ព្រំដែនដូចប្រកជាំអីចឹង?
សារឿនៈ ប្រកដូចជាំអីចឹង ។
បូលីៈ វាមិនខុសអីពីជាំស្រង៉ាំ និងជប់ម្លូទេ?
សារឿនៈ ជប់ម្លូ ជាំស្រង៉ាំនៅលើទឹកខ្មែរ ។
បូលីៈ ជប់ម្លូនៅដីថៃ ហើយទល់មុខគ្នាជាមួយជាំស្រង៉ាំ?
សារឿនៈ ទន្ទឹមគ្នា ។
បូលីៈ ជប់រុនដីខ្មែរ ដល់ជាំស្វាទល់មុខជប់រុន?
សារឿនៈ នៅពីក្រោយ ទៅចេះ ។
បូលីៈ អីចឹងអូរត្រាវ ស៊ឹងចាន់ នៅចន្លោះហ្នឹង?
សារឿនៈ នៅចន្លោះ ពីខាងកើតជប់ម្លូ មកជាំស្វា នៅចន្លោះប៉ុណ្ណឹង ។
បូលីៈ បានន័យថាអានេះជាំស្វា អានេះជប់ម្លូ ។ អូរត្រាវ ដងទង់ វានៅម្តុំហ្នឹង ។
សារឿនៈ វានៅចន្លោះហ្នឹងទាំងអស់ ។

បូលីៈ    អូរ៤០នៅចន្លោះហ្នឹងដែរ?
សារឿនៈ  អូរ៤០ក៏នៅចន្លោះហ្នឹងដែរ។
បូលីៈ    ៥០នៅចន្លោះហ្នឹងដែរ?
សារឿនៈ  ៥០នេះ ជប់រុនវិញ។
ដានីៈ    មកជប់រុនវិញ?
សារឿនៈ  មកជប់រុននេះវិញ ក្នុងចន្លោះជប់រុន ក្នុងចន្លោះ។
បូលីៈ    ៥០ង៉ាកមកខាងកើតតិច?
សារឿនៈ  ខាងកើតជប់រុនតិច ដីប្រហែលជា១គីឡូ។
បូលីៈ    បើប្រោកនៅប្រឡោះហ្នឹង?
សារឿនៈ  នេះអន្លង់វែង ចន្លោះហ្នឹងហើយ នេះទីតាំងខ្មែរក្រហម។
បូលីៈ    អីចឹងយើងអាចនិយាយបានថាអានេះទល់ដែនអន្លង់វែង នេះទល់ដែនត្រពាំងប្រាសាទ។
សារឿនៈ  ជប់រុន។
បូលីៈ    ជប់រុននៅម្តុំនេះ។
សារឿនៈ  បាទ!
បូលីៈ    ដែនរបស់ត្រពាំងប្រាសាទនៅនេះជាមួយព្រះវិហារ ប្រឡោះហ្នឹងគឺខ្មែរក្រហមនៅម្តុំហ្នឹង?
សារឿនៈ  នៅម្តុំហ្នឹងត្រូវហើយ។
បូលីៈ    រាយប៉ាយម្តុំហ្នឹង?
សារឿនៈ  រាយប៉ាយមុខក្រោយៗគ្នាអីចឹង។
បូលីៈ    យើងមិនដឹងអាណាជាំស្វា អាណាអីយើងគ្រាន់តែដឹងថានៅម្តុំហ្នឹង?
សារឿនៈ  បាទ! នៅម្តុំហ្នឹង។
បូលីៈ    បើចង់ដៅទីតាំងឲ្យដឹងច្បាស់ថាទីតាំងមួយណាជាមួយណា ទាល់តែយកដែនទីថៃមកមើល។
សារឿនៈ  បាទ។
បូលីៈ    ហើយលំអិតទៅលើភូមិ-ឃុំរបស់ថៃហ្នឹងទៀត?
សារឿនៈ  ដល់អីចឹងបានច្បាស់។
បូលីៈ    អីចឹងបានធ្វើបាន។
សារឿនៈ  ព្រោះឈ្មោះពេលនោះយើងចេះតែឲ្យ ឃើញម្ចូថាម្ចូ។
បូលីៈ    ឃើញម្ទេសថាម្ទេស?

សារឿនៈ យើញម្ទេស ចំការម្ទេសដាក់ថាម្ទេសអីចឹងទៅ យើងអត់មានអីប្រាកដ តែជាំស្វាឈ្មោះ ថៃ អូរគ្រាវឈ្មោះថៃ ។

ដានីៈ បើសិនជាឈ្មោះធំៗ ព្រះប្រឡាយ ជប់រុន ជាំស្រង៉ាំ ជាំស្វា ហ្នឹងវាមានឈ្មោះដល់ឥឡូវ

សារឿនៈ បាទ!

បូលីៈ យើងអាចដៅបាន ។

សារឿនៈ យើងអាចដៅ ។

ដានីៈ ដូចចំការម្ទេសបាត់ហើយមើលទៅ?

សារឿនៈ បាត់ហើយព្រោះវានៅជប់រុន ។

ដានីៈ គេដាំម្ទេស?

សារឿនៈ គេដាំម្ទេស គេហៅឈ្មោះចំការម្ទេស ។

បូលីៈ ចំការម្ទេសពីណាអ្នកដាំ?

សារឿនៈ ចំការម្ទេសពួកកងទ័ពដាំ ។

បូលីៈ មិនមែនថៃទេ?

សារឿនៈ មិនមែនថៃទេ ចំការម្ទេស ចំការម្ចាស់ខ្មែរដាំ ។

បូលីៈ អីចឹងចេះតែហៅចំការម្ទេស?

សារឿនៈ ចេះតែហៅចំការម្ទេស ចំការម្ចាស់ជានាម ។

បូលីៈ ឈ្មោះស៊ឹងចាន់ដូចមានលក្ខណៈជាខ្មែរជាងបើយើងមើលសំលេងវាទៅ ស៊ឹងចាន់?

សារឿនៈ របស់ថៃ ស៊ឹងខ្មែរយើងហៅ ។

បូលីៈ តែភាសាថៃមិនមែនស៊ឹងចាន់ទេ?

សារឿនៈ មិនដឹងយ៉ាំងម៉េច ។

បូលីៈ អ៊ំអត់ដែលលឺសូរភាសាថៃទេ?

សារឿនៈ អត់ដែលលឺដែល គេហៅហួយចាន់ តែខ្មែរយើងបកប្រែពីហួយមកស៊ឹង អូរ មិនដឹងដល់ស៊ឹងទេ អូរតូច គ្រាន់តែវារមៀលក្រោយមក តូចទទឹងប្រហែលពីនេះទៅដើមនោះចុះប៉ុណ្ណឹងហ្នឹង ។

បូលីៈ ហ្នឹងស៊ឹងគេ?

សារឿនៈ បាទ! យើងចេះតែហៅង៉ារ គេហៅស៊ឹងៗ ។

បូលីៈ តែមានទឹកប្រើទេ?

សារឿនៈ ទឹកអត់ដាច់ ព្រោះនៅហ្នឹងសុទ្ធតែខ្មែរសុរិន្ទ គាត់ហៅស៊ឹងចាន់តាមខ្មែរសុរិន្ទ ។

ដានី៖ គាត់និយាយភាសាខ្មែរ?

សារឿន៖ គាត់និយាយភាសាខ្មែរ ។

បូលី៖ មានភូមិថៃនៅក្នុងហ្នឹងទេ?

សារឿន៖ ក្នុងហ្នឹងភូមិ ចំការគេមាន ចំការខ្ទមគ-៤ ដល់ពេលយើងទៅនៅ ថៃគេឲ្យប្រជាជនហ្នឹងថយសិនទៅ គេឲ្យថយទៅនៅភូមិវិញ ឲ្យប្រជាជនខ្មែរនៅ ។

ដានី៖ ថៃកាលហ្នឹងចិត្តល្អម្ល៉េះ?

សារឿន៖ ថៃជួយខ្មែរទាំងស្រុង ។

បូលី៖ គេចរចារពីលើមកហើយ!

សារឿន៖ គេចរចារពីលើត្រូវហើយ សូម្បីតែចំការដំឡូងប្រជាជនភៀសខ្លួនចេញទៅ អស់ប៉ុន្មានក៏គេអត់គិតដែលថៃ ។ ប្រជាជនខ្មែរយើងដែលភៀសខ្លួនហ្នឹង ទៅរាប់ពាន់នាក់ ទៅដល់ខ្ទិចមួយចំការក៏មានដែរ តែគេប្រកាសប្រាប់ប្រជាជនថៃថាកុំឲ្យមាត់អី បញ្ហាប៉ុន្មាន១ារ ២ារ ដែលអស់ហ្នឹងទៅទូទាត់លុយជាមួយតាម៉ុក គេប្រកាសអីចឹងហើយស្រេច យកជាលុយយកជាអីគេ គេត្រៀមទូទាត់កុំឲ្យមានបញ្ហាជាមួយជនភៀសខ្លួន គេបើកទូលាយអីចឹង ។

បូលី៖ អីចឹងយើងមានទំនាក់ទំនងជាមួយនឹងប្រជាជនថៃនៅតាមទល់ដែនហ្នឹងដែរ?

សារឿន៖ ប្រជាជនថៃនៅតាមកន្លែងយើងមួយៗ ប្រជាជនថៃមកលក់នំ ចេក អំពៅ តាមជំរំយើងកងទ័ពនៅ យើងមានអង្ករ សាប៊ូ ត្រីកាម៉ុង អាត្រីផ្លាខូយើងហ្នឹង ដូរអង្ករ អំបិល ប៊ីចេងជាមួយគាត់ហ្នឹងហូបទៅ ។

បូលី៖ ចំងាយពីតំបន់ យើងហៅតំបន់ចុះព្រោះក្នុងហ្នឹងវាអត់មានភូមិ មានឃុំ ស្រុកត្រឹមត្រូវនៅដីគេ ។ ចំងាយពីតំបន់ដែលខ្មែរក្រហមរស់នៅជុំៗ មកភូមិរបស់ថៃប្រហែលប៉ុន្មានគីឡូ?

សារឿន៖ ប្រហែលជាមានជិត មានឆ្ងាយ មានភូមិខ្លះជាប់១០គីឡូ ។

បូលី៖ ហ្នឹងជិតបំផុត?

សារឿន៖ ជិត ។

បូលី៖ ១០គីឡូ!

សារឿន៖ មានភូមិខ្លះ១៥គីឡូ ព្រោះខ្ញុំដើរទៅភូមិថៃ ទៅរកទិញអីយកមកហូប ឆ្ងាយណាស់ដើរទៅមកមួយព្រឹកថ្ងៃត្រង់ល្មម ។

បូលី៖ ដើរថ្មើរជើង?

សារឿន៖ បាទ! ថ្មើរជើងពីជំរំទៅ ។

ដានី៖ យើងគិតថាមួយម៉ោងយើងដើរបាន៤គីឡូ ។

សារឿនៈ ៣គីឡូកន្លះ-៤គីឡូ ដើរបៀបអីចឹង៣គីឡូកន្លះ មួយព្រឹកទៅទិញអីហើយ តែទិញអត់ដល់ភូមិគេទេ ឧទាហរណ៍ភូមិគេនៅអីចឹង យើងទិញប្រហែល២០០ម៉ែត្រពីភូមិគេ មើលឃើញដើមដូង ដើមត្នោត ។ ប្រជាជនយកមកលក់ឲ្យ យើងទិញយកមក ។

បូលីៈ អាជ្ញាធរគេអត់មានរិតបន្តឹងចំពោះការដើរហើររបស់យើងទេ? អាជ្ញាធរថៃ?

សារឿនៈ ដូចអត់ដែលលឺសូរអី តែខ្មែរក្រហមមិនងាយដើរផ្ដេសផ្ដាសទេ មិនងាយដើរលេងជិះ ភូមិប្រជាជនទេ មានអ្នកខិលខូចដើររកស៊ីជួញដូរកាឆា ទៅដល់ភូមិដីងហើយដើរដឹកគោ បើអ្នកធ្វើការងារគេតែម្ដងអត់ទៅទេ អត់មានឲ្យពាក់ព័ន្ធជាមួយប្រជាជនថៃទេ បើដូរតាមចំការមាន ។

បូលីៈ មានអ្នកទៅរស់នៅក្នុងភូមិថៃទេ?

សារឿនៈ អត់ទេ ។

បូលីៈ អត់សោះតែម្ដង?

សារឿនៈ អត់សោះតែម្ដង បើដេកតាមខ្ទម១-២យប់មាន បើថាឲ្យទៅនៅក្នុងភូមិអត់មានទេ ។

ដានីៈ ចន្លោះពីត្រពាំងប្រាសាទ មកអន្លង់វែងនេះ ចំងាយដីប្រហែលប៉ុន្មានគីឡូដែរ?

សារឿនៈ ពីខ្សែស្របលេខប៉ុន្មាននៅអន្លង់វែង?

បូលីៈ អានេះវាអត់មានដាក់លេខ ។

សារឿនៈ បើស្រុកត្រពាំងប្រាសាទនៅលេខ១០ ។

បូលីៈ នេះលេខ៨? អេ៎! លេខ៨មិនមែននៅក្នុងអន្លង់វែងទេ?

សារឿនៈ លេខ៨នៅក្នុងអន្លង់វែង ព្រោះលេខ១០, លេខ៩, លេខ៨, លេខ៧ រហូតដល់លេខ១ តាទុំខ្សែស្រប ។

បូលីៈ លេខ១នៅតាទុំ?

សារឿនៈ បាទ! ហើយមកដល់លេខ១០គេខិតព្រំដែនមកត្រពាំងប្រាសាទ លេខ១០ទន្ទឹងទួលគ្រួស ស្គាល់ទួលគ្រួសទេ?

ដានីៈ ស្គាល់ ។

សារឿនៈ គេដាក់ព្រំប្រទល់ស្រុក ។

ដានីៈ សាច់ស្អុយ សាច់ហើម ។

សារឿនៈ យើងមើលទៅលើភ្នំក៏ចំណុចហ្នឹងដែរ ។

បូលីៈ អីចឹងបានន័យថាលេខ១០ហ្នឹងគឺព្រំប្រទល់ត្រពាំងប្រាសាទ អន្លង់វែង?

សារឿនៈ បាទ ។

បូលីៈ នេះលេខ១០?

សារឿនៈ លេខ៩អន្លង់វែង លេខ១០ត្រពាំងប្រាសាទ ។

បូលីៈ ចុះព្រំប្រទល់ត្រពាំងប្រាសាទខាងនេះ ជាមួយព្រះវិហារលេខប៉ុន្មាន?

សារឿនៈ លេខ៤០ដល់បង្គោល៨ គិតទៅខ្សែស្របលេខប៉ុន្មាន ដូច២៥ ។

បូលីៈ មួយប្រឡោះប៉ុន្មានគីឡូ?

សារឿនៈ មួយប្រឡោះមួយគីឡូ ដីនេះតូច ។

បូលីៈ ប្រហែលប៉ុន្មានប្រឡោះចាប់ពីនេះមកនេះ?

សារឿនៈ បើគិតទៅខ្សែស្របលេខ១០មកដល់លេខ២៥ ។

បូលីៈ មកណាវិញលេខ២៥? មកត្រពាំងប្រាសាទ?

សារឿនៈ មកកើត ។

បូលីៈ អីចឹង២៥គីឡូ?

សារឿនៈ អាច២៥-៣០ ។

បូលីៈ អានេះអាច២៥គីឡូទៀតទេ?

សារឿនៈ បាទ! ខ្ទង់ អន្លង់វែង?

បូលីៈ ពី១០មកអន្លង់វែងថយក្រោយវិញ?

សារឿនៈ ថយក្រោយមកដល់អន្លង់វែង យើងធ្លាក់ទៅដល់តាទុំមិនដឹងប៉ុន្មានទេ ។

ដានីៈ ពីព្រោះមើលទៅចន្លោះនេះទៅចន្លោះប្រហែលគ្នា ។

សារឿនៈ បាទ! ប្រហែលគ្នា ។

បូលីៈ បើសិនជាពីលេខ១០នេះមកទល់ដែនត្រពាំងប្រាសាទ-ព្រះវិហារ ២៥គីឡូ អានេះក៏ប្រហាក់ប្រហែល២៥គីឡូដែរ?

សារឿនៈ បាទ!

ដានីៈ អានេះពីលេខ១០មកដល់លេខ២៥?

សារឿនៈ បាទ! មកដល់២៥ ។

ដានីៈ ចុះមួយលេខប្រហែល១គីឡូ ១៥គីឡូ ។

សារឿនៈ ដែនទីខ្នាត២,៥គីឡូហ្នឹង ។

ដានីៈ មួយលេខ២,៥គីឡូ ។

បូលីៈ ខ្ញុំអត់ច្បាស់ ។

សារឿនៈ បងឯងទៅមើលលេខបញ្ជរឃើញលេខគេដាក់ហើយ ។

បូលីៈ អីចឹងយើងមិនទាន់វៃតំលៃថាបានប៉ុណ្ណា ។

សារឿនៈ អត់ទាន់បានប៉ុន្មានទេ មើលដែនទី ។

បូលីៈ ទៅមើលភូមិសាស្រ្តដឹងហើយ ប៉ុន្មានគីឡូ ។

សារឿនៈ ដឹងតែលេខ១០មកកើត ទល់ព្រះវិហារ អូរទឹកខៀវ ។ ដែលឃើញអូរទឹកខៀវ?

ដានីៈ អត់ដែរ ។

សារឿនៈ ដែលជិះឡានតាមផ្លូវនេះទេ?

ដានីៈ បាទ!

សារឿនៈ ទៅកើតចេះ ទៅស្រអែមនៅពាក់កណ្តាលពីនេះទៅមានគេដាក់ជំរំកងរាជអាវុធហត្ថ គេដាក់ស្នាក់ការ ។

បូលីៈ កងពលលេខ៨?

សារឿនៈ អត់ទេ ខាងនេះលេខ៨ ។

បូលីៈ មកខាងនេះវិញ?

សារឿនៈ មកខាងនេះមានអូរមួយគេដាក់ស្នាក់ការកងរាជអាវុធហត្ថស្រុកត្រពាំងប្រាសាទ ត្រឹមហ្នឹងហើយព្រំប្រទល់ ទៅពីផ្ទះអ៊ំប៉ោងតិចទៅ ។

បូលីៈ ព្រំប្រទល់ព្រះវិហារជាមួយត្រពាំងប្រាសាទ?

សារឿនៈ ត្រពាំងប្រាសាទ ស្នាក់ការបេអ៊ឹម ។

បូលីៈ ហ្នឹងអូរទឹកខៀវ?

សារឿនៈ ឡើងទៅលើចេះទៅតាមអូរហ្នឹងរហូត ។

បូលីៈ អីចឹងអាចថាអូរទឹកខៀវនៅម្តុំនេះ?

សារឿនៈ មិនដឹងត្រង់ណា ។ ណាជប់រុន?

បូលីៈ នេះជប់រុន?

សារឿនៈ ហ្នឹងឯងនៅខាងកើតហ្នឹង ។

បូលីៈ ខាងកើតជប់រុនបន្តិច?

សារឿនៈ ខាងកើតជប់រុន២-៣គីឡូ ខាងកើតអូរ៥០ ។

បូលីៈ អូរទឹកខៀវហ្នឹងព្រំដែនព្រះវិហារ ។ ខាងកើតអូរ៥០ទៀត?

សារឿនៈ បាទ! ខាងកើតអូរ៥០ ។

ដានីៈ វាចំព្រំដែនតែម្តង?

សារឿនៈ ចំព្រំដែនគេកាត់សម័យថ្មីទេ ។

បូលីៈ នេះខ្សែព្រំដែនព្រះវិហារ ។

សារឿនៈ ព្រះវិហារពីមុននៅនេះ ដល់សមាហរណកម្មគេកាត់ឲ្យចូលមកឧត្តរមានជ័យ បើតាមព្រះវិហារនេះក៏ទឹកដីកំណើតដែរ នោះត្រឹមអូរនោះ ទួលប្រាសាទ ។

បូលីៈ ផ្លូវដែលអ៊ំដើរទៅហ្នឹង ដើរមកភូមិថៃផ្លូវយ៉ាងម៉េច? ផ្លូវដី ផ្លូវថ្នល់ ឬផ្លូវលំ?

សារឿនៈ ផ្លូវដើង ផ្លូវរទេះ ផ្លូវគោយន្ត ។

បូលីៈ ប៉ុនៗណា?

សារឿនៈ ផ្លូវគោយន្ត ផ្លូវប៉ុនៗរលុបៗ ។

បូលីៈ បានស្អាតប៉ុនយើងឥឡូវហ្នឹងទេ?

សារឿនៈ អាផ្លូវធំនោះ?

បូលីៈ បាទ!

សារឿនៈ អត់ទេ ប៉ុនផ្លូវចូលផ្ទះខ្ញុំ ។

ដានីៈ រលុបៗអីចឹង?

សារឿនៈ រលុបៗអីចឹង ។

បូលីៈ រលុបអីចឹង ។

សារឿនៈ ផ្លូវគាត់ដឹកឈើ អូសរថយន្ត ។

បូលីៈ បើកឡានបានទេ?

សារឿនៈ អត់បានទេ មានតែផ្លូវឡានចូលធំ តាម៉ុក ធ្វើផ្លូវចូលមកជំរំ ។

បូលីៈ ផ្លូវដែលដឹកឈើពីខ្មែរទៅថៃ?

សារឿនៈ អត់ទេ ផ្លូវដឹកឈើ ជនជាតិថៃគាត់ដឹកឈើ យើងឃើញលំនាំជនជាតិថៃដឹកឈើពីព្រំដែនទៅស្រុកគាត់ យើងដើរតាមផ្លូវគាត់ដឹកឈើហ្នឹងទៅ អត់មានផ្លូវអីធំដុំទេ ហើយខ្មែរក្រហមដើរកាត់ពីជំរំមួយទៅជំរំមួយតែផ្លូវដើងទេ បើផ្លូវឡានដឹកចូលពីថៃត្រង់តាមជំរំមក

បូលីៈ នៅម្តុំនេះមានជំរំរបស់អង្គការសហប្រជាជាតិ? ជំរំជនភៀសខ្លួន?

សារឿនៈ អត់មានទេ ។

បូលីៈ អត់មានទេ ម្តុំនេះ?

សារឿនៈ មានតែក្រោយឆ្នាំ៩០ មានជំរំអូរត្រាវហ្នឹងមួយគត់ ។

បូលីៈ មានតែមួយគត់ជំរំអូរត្រាវហ្នឹង?

សារឿនៈ បាទ!

បូលីៈ បានន័យថាខ្មែរក្រហមដែលវៀតណាមរុញមកពីដើម៨៥ ដល់ចុង៨៩ អត់មានជីវិតរបស់អង្គការសហប្រជាជាតិទេ?

សារឿនៈ អត់មានទេ ។

បូលីៈ ទាល់តែខ្មែរក្រហមចុះទៅក្រោមបានអូរត្រាវ អង្គការសហប្រជាជាតិគ្រប់គ្រង?

សារឿនៈ អង្គការសហប្រជាជាតិ ។

បូលីៈ ចុះភូណាយ ដែលក្រោយមក៩៨-៩៩?

សារឿនៈ ភូណាយសម័យ៩៨-៩៩នេះ ។

បូលីៈ មុំណាអ៊ំ?

សារឿនៈ មុំចំការកៅស៊ូ ។

បូលីៈ ទល់មុខណា?

សារឿនៈ ទល់មុខអន្លង់វែងហ្នឹងដែរ ។

ដានីៈ ជាំហ្នឹងដែរ?

សារឿនៈ ជាំហ្នឹងដែរ គេហៅភូណាយៗហ្នឹងភ្នំ ។

ដានីៈ ហ្នឹងជិតជប់ម្ហូបអត់ទេ?

សារឿនៈ អាហ្នឹងដូចហួសជប់ម្ហូទៅក្រោយបន្តិច ។

ដានីៈ ក្រោយជប់ម្ហូទៀត?

សារឿនៈ ក្រោយជប់ម្ហូតិច ។

ដានីៈ ហួសជប់ម្ហូទៀត?

សារឿនៈ ហួសជប់ម្ហូបន្តិចទៀត ។

បូលីៈ អាចមុំអូរត្រាវទេមើលទៅ?

សារឿនៈ អត់ទេ អត់មានដល់អូរត្រាវទេ ។

ដានីៈ ខាងនេះអូរត្រាវ?

សារឿនៈ វានៅខាងនេះអូរត្រាវទៀត ។

បូលីៈ ខាងលិច ឬខាងកើត?

សារឿនៈ នៅខាងអន្លង់វែង កៀកអន្លង់វែងជាងភូណាយហ្នឹង ព្រោះភូណាយហ្នឹងគេឲ្យឈ្មោះថាជំរំរបស់តាម៉ុក ចុងក្រោយ ព្រោះកាលពីកំលាំងខ្ញុំផ្តាច់ខ្លួនចូលរាជរដ្ឋាភិបាលហើយ តាម៉ុកសេសសល់មួយចំនួន គាត់រត់ទៅនៅភូណាយហ្នឹង តែប៉ុណ្ណឹងទេ ថ្មីសុទ្ធ ដែលទៅនៅភូណាយ

ហ្នឹងពួកហ្នឹងចុះមកអស់គេហៅជីវិភូណាយ ជាជីវិបណ្ដោះអាសន្នរបស់គាមុ៉កទេ ក្នុងរយៈពេល៦-៧ខែហ្នឹង តែប៉ុណ្ណឹង ។

ដានីៈ ភូណាយហ្នឹងឈ្មោះរបស់ថៃ ភូមិរបស់គេ ឬយ៉ាងម៉េច?

សារឿនៈ របស់ថៃ ។

ដានីៈ ឈ្មោះអីគេ ភូណាយហ្នឹង?

សារឿនៈ ភូណាយៗគេហៅថាភ្នំតូច ។

បូលីៈ ប្រែមកថាភ្នំតូច ។

សារឿនៈ ថាទំនប់តូច ។ ភូៗ"ភ្នំ" ណាយៗហ្នឹងតូច តិច ។

ដានីៈ តែភូណាយ និងកន្លែងអូរត្រាវ កន្លែងវាខុសគ្នា?

សារឿនៈ ខុសគ្នា ឆ្ងាយពីគ្នាណា ។

ដានីៈ ដូចថាអូរត្រាវហ្នឹងកន្លែងដែលពូមានប្រសាសន៍មិញយើងដៅកន្លែង មុំ៤០ ស៊ីងចាន់ ហ្នឹងអូរត្រាវ ដល់ពេលភូណាយបើយើងចេញពីជាំមកត្រង់ដល់ជប់ម្ហូ អីចឹងទេ?

សារឿនៈ ចាំមើល ចេញពីជាំវាផ្លូវមួយមកភូណាយ ផ្លូវមួយបែកមកចេះទៀត ជប់ម្ហូនៅខាងនេះ វានៅបញ្ជិតគ្នា ។

បូលីៈ បញ្ជិតខាងនេះវិញ?

សារឿនៈ បញ្ជិតខាងកើតជប់ម្ហូ ។

ដានីៈ ខាងនេះភូណាយ ជប់ម្ហូមកនៅខាងនេះវិញ ។

សារឿនៈ បាទ នៅខាងកើតបន្តិច ។

បូលីៈ អីចឹងបានន័យថាភូណាយខាងកើតជប់ម្ហូ តែមិនដល់អូរត្រាវទេ ។

សារឿនៈ អត់ទេ ឆ្ងាយពីអូរត្រាវណាស់ ។

បូលីៈ អូរត្រាវវានៅជ្រៅដីថៃ ។

សារឿនៈ ជ្រៅហ្នឹងទៀតអូរត្រាវ គ្រាប់ផ្លោងអត់ដល់ទេពីព្រំដែនទៅ ។

ដានីៈ លោកពូដោយសារពេលវេលាវាយប់ដែលហើយ អីចឹងខ្ញុំគិតថាយើងសំរាកត្រឹមហ្នឹង បើសិនជាមានពេលជួបលោកពូទៀត យើងអាចបន្តពីហ្នឹងមក បន្តទៀត អីចឹងពួកខ្ញុំអរគុណលោកពូច្រើនដែលបានផ្ដល់ ដូចថាទាក់ទងពីបទពិសោធន៍លោកពូដែលបានឆ្លងកាត់ធ្លាប់ស្គាល់កន្លែង ។

សារឿនៈ បាទ ។

ដានីៈ អីចឹងខ្ញុំអរគុណច្រើនលោកពូ ។

សារឿនៈ    បាទ!

ចប់